ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# គោលការណ៍ណែនាំស្ដីពី កិច្ចការពារកុមារលើប្រព័ន្ធអនឡាញ សម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល នៅកម្ពុជា

២០២៣



unicef for every child

End Violence Against Children

# មាតិកា


**១. សេចក្ដីផ្ដើម** ... ៦

១.១ គោលបំណងនៃគោលការណ៍ណែនាំ ... ៩

**២. ជំហានសំខាន់ៗដែលក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលត្រូវអនុវត្តនៅកម្ពុជា** ... ១១

២.១ ការវាយតម្លៃផលប៉ះពាល់សិទ្ធិកុមារ ... ១២

២.២ ការបង្កើត និងអនុវត្តនីតិវិធីផ្ទៃក្នុង ... ១៣

២.៣ គោលការណ៍រចនាប្រកបដោយសុវត្ថិភាព ... ១៣

២.៤ ការគាំទ្រនិងលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពលើប្រព័ន្ធអនឡាញ ... ១៤

២.៥ ការបង្កើតបរិស្ថានសុវត្ថិភាពលើប្រព័ន្ធអនឡាញ ... ១៥

២.៦ ការទប់ស្កាត់និងការឆ្លើយតបទៅនឹងរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ CSAM ... ១៦

**៣. ការវាយតម្លៃលទ្ធផលនៃការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល** ... ២៤

**ឧបសម្ព័ន្ធ ក៖ អាយុ និងដំណាក់កាលនៃការវិវត្តរបស់កុមារ** ... ២៥

**ឧបសម្ព័ន្ធ ខ៖ បញ្ជីត្រួតពិនិត្យអនុលោមភាពនៃការឆ្លើយតបរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល** ... ៣០

**ឧបសម្ព័ន្ធ គ៖ សន្ទានុក្រម** ... ៣៤

# អារម្ភកថា



ដោយពិនិត្យឃើញហានិភ័យនិងកំណើនគ្រោះថ្នាក់កើតមានឡើងច្រើននៅលើបណ្តាញអ៊ីនធឺណិតចំពោះកុមារកម្ពុជា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានរៀបចំគោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជាអនុវត្ត។ គោលការណ៍ណែនាំនេះមានគោលដៅសំខាន់ជំរុញឱ្យក្រុមហ៊ុនបច្ចេកវិទ្យាចាប់យកយន្តការបង្ការប្រកបដោយប្រសិទ្ធភាពមួយចំនួនដើម្បីធានាថាសេវា និងផលិតផលរបស់ខ្លួនមានសុវត្ថិភាពចំពោះកុមារ និងអាចឆ្លើយតបទាន់ពេលវេលាទៅនឹងគ្រោះថ្នាក់នានាដែលកើតមាន។

ជាការពិតជាក់ស្តែង បច្ចេកវិទ្យាឌីជីថលគឺជាឧបករណ៍ដ៏មានសក្តានុពលនៅក្នុងការអភិវឌ្ឍប្រទេស និងផ្តល់នូវអត្ថប្រយោជន៍ព្រមទាំងឱកាសមហិមាសម្រាប់ប្រជាពលរដ្ឋទូទៅរួមទាំងកុមារផងដែរ។ ស្ថិតិនៃការប្រើប្រាស់អ៊ីនធឺណិតបច្ចុប្បន្នបានបង្ហាញថាក្នុងចំណោមមនុស្ស ៣នាក់ មានម្នាក់គឺជាកុមារ។ ចំនួននេះបានកើនឡើងជាបន្តបន្ទាប់ក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ ដោយសារបច្ចេកវិទ្យាឌីជីថល បានក្លាយជាឧបករណ៍ដ៏ចាំបាច់សម្រាប់កុមារទាក់ទងគ្នា ស្រាវជ្រាវ និងសិក្សារៀនសូត្រ។ សន្ទុះនៃការប្រើប្រាស់នឹងមិនមានការធ្លាក់ចុះឡើយ ដោយហេតុថាក្នុងដំណើរការអភិវឌ្ឍប្រទេសកម្ពុជានាបរិបទបដិវត្តឧស្សាហកម្ម៤.0 រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។ ក្របខណ្ឌគោលនយោបាយទាំងពីរ បានបង្ហាញពីចក្ខុវិស័យវែងឆ្ងាយក្នុងការប្រែក្លាយកម្ពុជាឆ្ពោះទៅក្នុងដំណាក់កាលវិវត្តថ្មីមួយទៀតដែលក្នុងនោះបច្ចេកវិទ្យាឌីជីថលនឹងត្រូវបានប្រើប្រាស់សម្រាប់ការធ្វើបរិវត្តកម្មគ្រប់វិស័យ ទាំងក្នុងជួររាជរដ្ឋាភិបាល អាជីវកម្ម និងប្រជាពលរដ្ឋ។ គោលបំណង គឺដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី លើកកម្ពស់សុខុមាលភាពសង្គម ការផ្តល់នូវសេវាសាធារណៈកាន់តែប្រសើរឡើង។ ក្នុងន័យនេះ ប្រជាពលរដ្ឋគ្រប់រូបត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីប្រែក្លាយខ្លួនជាពលរដ្ឋឌីជីថលស្របតាមចក្ខុវិស័យកំណត់ទុក។ ហេតុនេះ ដើម្បីធានាអំពីដំណើរការវិវត្តនៃសេដ្ឋកិច្ចនិងសង្គមឌីជីថលទៅដោយរលូន និងផលប្រយោជន៍ពិតប្រាកដចំពោះប្រជាពលរដ្ឋគ្រប់រូប ការគិតគូរពីសុវត្ថិភាព និងសុខុមាលភាពឌីជីថលគឺជាអាទិភាពដ៏សំខាន់។

ក្នុងចំណោមអ្នកប្រើប្រាស់ទាំងអស់  កុមារគឺជាជនងាយរងគ្រោះជាងគេនៅលើប្រព័ន្ធអនឡាញ។ ហេតុដូច្នេះ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅក្នុងអនុសាសន៍ទូទៅលេខ២៥ ដែលត្រូវបានអនុម័តនៅឆ្នាំ២០២១ សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃបរិយាកាសឌីជីថលចំពោះជីវិត និងសិទ្ធិរបស់កុមារ។ នៅលើអនឡាញ កុមារអាចងាយប្រឈមនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ការធ្វើបាបសម្លុតគម្រាមកំហែង ការល្បួងតាមអនឡាញ ការចែកចាយរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទ និងការធ្វើត្រាប់តាមឥរិយាបថមិនល្អជាដើម។ ហានិភ័យ និងគ្រោះថ្នាក់ទាំងឡាយនេះ អាចទប់ស្កាត់ និងកាត់បន្ថយបានដោយការចូលរួមការពារ និងដោះស្រាយពីភាគីពាក់ព័ន្ធមានទាំងរាជរដ្ឋាភិបាល អ្នកអនុវត្តច្បាប់ ឪពុកម្តាយ អាណាព្យាបាល គ្រូបង្រៀន អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល និងកុមារខ្លួនឯងផ្ទាល់។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាក្រសួងទទួលបន្ទុកលើការអភិវឌ្ឍឌីជីថលបានដើរតួនាទីសំខាន់មួយក្នុងការបង្កើតគោលការណ៍ណែនាំជាលក្ខណៈបច្ចេកទេស ស្របតាមស្តង់ដារជាតិ និងអន្តរជាតិ ដើម្បីក្រុមហ៊ុនបច្ចេកវិទ្យាអនុវត្ត។ គោលការណ៍នេះគឺដើម្បីធានាថាសេវា និងផលិតផលឌីជីថលរបស់ក្រុមហ៊ុនទាំងឡាយ បង្កើតឡើងដោយមានការគិតគូរគោរពដល់គោលការណ៍ជាមូលដ្ឋាននិងសិទ្ធិរបស់កុមារ និងគោលការណ៍អាជីវកម្ម។ ប៉ុន្តែដើម្បីអាចឱ្យប្រព័ន្ធកិច្ចការពារកុមារមានប្រសិទ្ធិភាពខ្ពស់ទាមទារការចូលរួមពីភាគីពាក់ព័ន្ធគ្រប់ផ្នែក។

ការបង្កើតគោលការណ៍នេះអាចប្រព្រឹត្តទៅបានដោយមានការចូលរួមគាំទ្រពីភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា ក្រសួងស្ថាប័នរាជរដ្ឋាភិបាល វិស័យឯកជនដៃគូរពាក់ព័ន្ធនានា និងក្រុមការងារបច្ចេកទេសក្រសួង។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមយ៉ាងសកម្មក្នុងការរៀបចំគោលការណ៍ណែនាំនេះឡើងប្រកបដោយលទ្ធផលខ្ពស់ ហើយសូមអំពាវនាវដល់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលទាំងអស់ចូលរួមអនុវត្តតាមគោលការណ៍ណែនាំនេះដើម្បីធានានូវសុខសុវត្ថិភាព និងសុខុមាលភាពសម្រាប់កុមាររបស់យើងនៅក្នុងសម័យឌីជីថល។  ការធានានូវបរិស្ថានឌីជីថលដែលគ្មានហានិភ័យសម្រាប់កុមារគឺជាទំនួលខុសត្រូវរបស់យើងគ្រប់គ្នា។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**



# ១. សេចក្តីផ្តើម

គោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា ត្រូវបានរៀបចំឡើងបន្ទាប់ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានវិភាគស្ថានភាពអំពីភាពរួចរាល់របស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅក្នុងប្រទេសកម្ពុជាក្នុងការបង្ការទប់ស្កាត់ និងឆ្លើយតបទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារ និងអំពើហិង្សាលើកុមារក្នុងទម្រង់ផ្សេងៗតាមប្រព័ន្ធអនឡាញ។[១] គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើង ឆ្លើយតបទៅនឹងតម្រូវការដែលកំណត់នៅក្នុងការវិភាគស្ថានភាពដំបូងរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងការសិក្សាអំពីការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា[២] និងការចង្អុលបង្ហាញក្នុងផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ២០២១-២០២៥។ ឯកសារគោលការណ៍ណែនាំនេះ គួរប្រើប្រាស់ដោយអមជាមួយឯកសារពន្យល់លម្អិតបន្ថែមទៀត។

**តើកិច្ចការពារកុមារលើប្រព័ន្ធអនឡាញគឺជាអ្វី?**

កិច្ចការពារកុមារសំដៅដល់ការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ នៅគ្រប់ស្ថានភាព និងបរិបទ។ កិច្ចការពារកុមារលើប្រព័ន្ធអនឡាញ គឺជាការទប់ស្កាត់ និងឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន នៅក្នុងលំហាឌីជីថល ព្រមទាំងទទួលស្គាល់ថាអ្វីដែលកើតឡើងនៅលើអនឡាញ មិនមែនត្រឹមតែមាននៅក្នុងលំហាឌីជីថលទេ ប៉ុន្តែវាមានទំនាក់ទំនងយ៉ាងស៊ីជម្រៅជាមួយ នឹងអ្វីដែលកើតឡើងនៅក្រៅប្រព័ន្ធអនឡាញ។ លំហាឌីជីថលគឺជាបរិបទមួយដែលអំពើហិង្សាអាចកើតឡើងតាមរយៈការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា។

គោលការណ៍ណែនាំថ្នាក់ជាតិនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើសិទ្ធិកុមារនិងគោលការណ៍អាជីវកម្ម (Children's Rights and Business Principles-CRBP) ដែលបង្កើតឡើងដោយអង្គការយូនីសេហ្វ ក្លូបល ខមផែក (Global Compact) និងអង្គការសង្គ្រោះកុមារ (Save the Children) ដោយមានការទទួលស្គាល់ដោយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលលើអនុសាសន៍ទូទៅរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិលេខ២៥ ស្តីពីសិទ្ធិកុមារក្នុងបរិស្ថានឌីជីថល (UNCRC General Comment No.25)។

---

[១] Ministry of Post and Telecommunications (2022). Child Online Protection within the Cambodian Digital technology industry: Assessment report. Unpublished research report

[២] Kardefelt Winther, Daniel (2022). Disrupting Harm in Cambodia: Evidence on online child sexual exploitation and abuse, Innocenti Research Report, UNICEF Office of Research - Innocenti, Florence

អនុសាសន៍ទូទៅលេខ ២៥ បានចែងលម្អិតអំពីកាតព្វកិច្ចរបស់រដ្ឋសមាជិកក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដើម្បីធានាថាសិទ្ធិកុមារត្រូវបានគិតគូរដូចគ្នាទាំងនៅក្រៅនិងនៅលើប្រព័ន្ធឌីជីថល។ អនុសាសន៍ទូទៅនេះ ទាមទាររដ្ឋាភិបាលចាត់វិធាននានា ជាអាទិ៍ ការបង្កើត ការតាមដានត្រួតពិនិត្យ ការអនុវត្ត និងការវាយតម្លៃច្បាប់ បទដ្ឋានគតិយុត្ត និងគោលនយោបាយ ដើម្បីធានាថាក្រុមហ៊ុនទាំងឡាយគោរពទៅតាមកាតព្វកិច្ចរបស់ពួកគេក្នុងការការពារបណ្តាញ និងសេវាកម្មអនឡាញរបស់ខ្លួន ឱ្យជៀសផុតពីការប្រើប្រាស់ ឬប្រើជាមធ្យោបាយក្នុងការបង្កើតអំពើហិង្សា ឬរំលោភសិទ្ធិកុមារ រាប់បញ្ចូលទាំងសិទ្ធិទទួលបានការការពារនិងឯកជនភាព និងការផ្តល់ដំណោះស្រាយភ្លាមៗប្រកបដោយប្រសិទ្ធិភាពដល់កុមារ ឪពុកម្តាយ អាណាព្យាបាល។ អនុសាសន៍ទូទៅលេខ២៥ បានអំពាវនាវដល់រដ្ឋសមាជិក ជំរុញក្រុមហ៊ុនឯកជនធ្វើការវាយតម្លៃផលប៉ះពាល់ចំពោះសិទ្ធិកុមារ ដែលកើតចេញពីសេវានិងផលិតផលរបស់ពួកគេនៅក្នុងបរិស្ថានឌីជីថល។ រដ្ឋសមាជិកត្រូវត្រួតពិនិត្យ ការពារ និងចាត់វិធានការចំពោះក្រុមហ៊ុនទាំងឡាយណាដែលរំលោភសិទ្ធិកុមារ ដូចមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។[៣]

ចំណុចទាំងអស់ខាងលើនេះ បានបញ្ជាក់ច្បាស់លាស់ពីការទទួលខុសត្រូវរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ក្នុងការធានាថាផលិតផលរបស់ពួកគេមានសុវត្ថិភាពនិងមានការគោរពសិទ្ធិកុមារ ទាំងសិទ្ធិក្នុងការទទួលការការពារពីគ្រោះថ្នាក់ សិទ្ធិក្នុងការទទួលបានព័ត៌មាន សិទ្ធិក្នុងការចូលរួម និងសិទ្ធិទទួលបានការអប់រំ។ ការរក្សាសុវត្ថិភាព និងការគោរពសិទ្ធិកុមារត្រូវបញ្ចូលទៅក្នុងគ្រប់សេវា និងផលិតផលដែលក្រុមហ៊ុនបានបង្កើតឡើង។ ក្រៅពីនេះ រដ្ឋាភិបាលត្រូវធានាថា សកម្មភាពពាក់ព័ន្ធទាំងអស់ត្រូវបានអនុវត្ត និងត្រូវចាត់វិធានការនៅពេលដែលក្រុមហ៊ុនមិនគោរពសិទ្ធិកុមារ។ គោលការណ៍ណែនាំនេះ ជាវិធានការមួយរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាក្រសួងទទួលខុសត្រូវក្នុងវិស័យបច្ចេកវិទ្យាឌីជីថលក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជារដ្ឋហត្ថលេខីមួយក្នុងអនុសញ្ញាស្តីអំពីសិទ្ធិកុមារ។

គោលការណ៍នេះក៏មានសង្គតិភាពជាមួយនឹងផែនការសកម្មភាពអាស៊ាន ដើម្បីការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចនិងរំលោភបំពានតាមប្រព័ន្ធអនឡាញឆ្នាំ២០២១ គោលនយោបាយថ្នាក់ជាតិរួមទាំងគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញរបស់ក្រុមប្រឹក្សាជាតិដើម្បីកុមារឆ្នាំ២០២៣ និងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ជំពូក៦ (សេចក្តីព្រាងខែកុម្ភៈ ឆ្នាំ២០២៣)។ ថ្វីត្បិតតែគោលការណ៍នេះរៀបចំឡើងដើម្បីណែនាំដល់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលអនុវត្តនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏អាចអនុវត្តបានចំពោះក្រុមហ៊ុនបណ្តាញសង្គមអន្តរជាតិដែលឋិតនៅក្រៅយុត្តាធិការច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រោះគោលការណ៍ទាំងអស់នេះមានសង្គតិភាពជាមួយច្បាប់ និងបទដ្ឋានគតិយុត្តដែលគ្រប់គ្រងក្រុមហ៊ុនបណ្តាញសង្គមអន្តរជាតិទាំងនោះ។

ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលដែលមានប្រតិបត្តិការក្នុងប្រទេសកម្ពុជា ត្រូវអនុវត្តតាមគោលការណ៍ណែនាំដើម្បីទប់ស្កាត់និងឆ្លើយតបទៅនឹងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ។ ការបំពេញកាតព្វកិច្ចនេះ ក៏ស្របទៅតាមក្របខណ្ឌសកល និងតំបន់ដូចបានឆ្លុះបញ្ចាំងក្នុង CRBP។ ក្របខណ្ឌទាំងនោះរួមបញ្ចូលទាំងគំរូនៃការ

[៣] United Nations Committee on the Rights of the Child, 2021

ឆ្លើយតបថ្នាក់ជាតិ (Model National Response-MNR) ដើម្បីបញ្ចប់ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ យុទ្ធសាស្ត្រចំនួនប្រាំពីរដើម្បីបញ្ចប់អំពើហិង្សាលើកុមារ (INSPIRE) និងផែនការសកម្មភាពអាស៊ាន ដើម្បីការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចនិងការរំលោភបំពានតាមប្រព័ន្ធអនឡាញ។ ក្រុមហ៊ុនបច្ចេកវិទ្យាក៏គួរតែប្រកាន់ខ្ជាប់តាមគោលការណ៍ណែនាំរបស់សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ ដែលមានការចង្អុលបង្ហាញជាក់លាក់បន្ថែមទៀត។ ក្របខណ្ឌទាំងនោះត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ(UNGP) ស្តីពីអាជីវកម្ម និងសិទ្ធិមនុស្ស។ ក្នុងនោះមាន៖

- គំរូនៃការឆ្លើយតបថ្នាក់ជាតិ (MNR) ទាមទារឱ្យក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល អនុវត្តតាមដីកាជូនដំណឹងនិងដកចេញ រាយការណ៍អំពីការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ស្វែងរកដំណោះស្រាយដើម្បីបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងចូលរួមនៅក្នុងសកម្មភាពទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុនដោយផ្តោតលើកុមារ។

- យុទ្ធសាស្ត្រចំនួនប្រាំពីរដើម្បីបញ្ចប់អំពើហិង្សាលើកុមារ (INSPIRE) ជាយុទ្ធសាស្ត្រស្នូល ដែលមានការបង្កើតបរិស្ថានសុវត្ថិភាព រួមបញ្ចូលទាំងបរិបទឌីជីថល ព្រមទាំងកម្មវិធីអប់រំ និងបំណិនជីវិត។ យុទ្ធសាស្ត្រនេះគួរតែជាផ្នែកមួយនៃទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល។

- ផែនការសកម្មភាពអាស៊ាន ដើម្បីការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចនិងការរំលោភបំពានតាមប្រព័ន្ធអនឡាញមានចំណុចយុទ្ធសាស្ត្រចំនួន៧។ ក្នុងនោះ ចំណុចទី៧ បានចែងអំពីតួនាទីរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល នៅក្នុងការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (គ្រប់ទម្រង់ទាំងអស់នៃការកេងប្រវ័ញ្ច និងការរំលោភបំពានលើប្រព័ន្ធអនឡាញ)។ ដូចទៅនឹងគំរូនៃការឆ្លើយតបថ្នាក់ជាតិ (MNR) ដែរ ផែនការសកម្មភាពនេះមានការរួមបញ្ចូលការបង្កើតនិងការអនុវត្តដីកាជូនដំណឹងនិងដកចេញ ការបង្កើតយន្តការរាយការណ៍ប្រកបដោយប្រសិទ្ធភាពជាដើម។

កិច្ចការពារកុមារលើប្រព័ន្ធអនឡាញជាបញ្ហាស្មុគស្មាញដែលទាមទារការតាំងចិត្តការសម្របសម្រួលនិងការទទួលខុសត្រូវរបស់ភាគីជាច្រើនទាំងក្នុងវិស័យឯកជននិងរដ្ឋាភិបាល។ នៅក្នុងជួររាជរដ្ឋាភិបាលយើងមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដើរតួនាទីជាអ្នកសម្របសម្រួលការអនុវត្តផែនការសកម្មភាពការការពារកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញដោយសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាអន្តរក្រសួង អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល។ រីឯក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាស្ថាប័ននាំមុខទទួលបន្ទុកក្នុងការជំរុញការចូលរួមរបស់វិស័យឯកជនពាក់ព័ន្ធនឹងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ (មានអគ្គស្នងការនគរបាលជាតិ និងអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា) សុទ្ធតែមានតួនាទីសំខាន់ក្នុងកិច្ចការពារកុមារពីការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទ។ ចំណែកឯវិស័យឯកជនវិញ គេតែងឃើញមានការទម្លាក់ការទទួលខុសត្រូវតែទៅលើក្រុមហ៊ុនបណ្តាញសង្គម ប៉ុន្តែជាក់ស្តែង ក្រុមហ៊ុន

បច្ចេកវិទ្យាឌីជីថលទាំងអស់រួមមាន ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ក្រុមហ៊ុនផ្តល់សេវាផ្ទុកទិន្នន័យ អ្នកបង្កើតនិងផលិតមាតិកាព័ត៌មានក្រុមហ៊ុនបង្កើតសុសវែរ និងកម្មវិធីទូរស័ព្ទដៃ សុទ្ធតែមានតួនាទីសំខាន់ក្នុងការធានាសុវត្ថិភាពលើប្រព័ន្ធអនឡាញ និងការគោរពសិទ្ធិកុមារ។

## ១.១ គោលបំណងនៃគោលការណ៍ណែនាំ

- បង្កើតនូវស្តង់ដារួមមួយសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលទាំងអស់ដែលមានប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុវត្តដោយស្មើភាពគ្នា។
- ធានាបាននូវវិធីសាស្ត្ររួមនិងមានសង្គតិភាព ក្នុងការគិតគូរ និងការកាត់បន្ថយហានិភ័យលើប្រព័ន្ធអនឡាញដោយគោរពដល់សិទ្ធិសមូហភាព និងឧត្តមប្រយោជន៍របស់កុមារនៅក្នុងបរិស្ថានឌីជីថល។
- ជំរុញការសម្របសម្រួលរវាងភាគីពាក់ព័ន្ធទាំងអស់ ដែលមានតួនាទីចាំបាច់ក្នុងការបង្ការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាគ្រប់ទម្រង់តាមប្រព័ន្ធអនឡាញ រួមទាំងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ។
- ជំរុញការអនុវត្តរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលក្នុងស្រុក ស្របតាមគំរូនិងក្របខណ្ឌឧត្តមានុវត្តន៍សកលថ្នាក់តំបន់ និងថ្នាក់ជាតិ។

ថ្មីៗនេះ មានការកើនឡើងនូវនិន្នាការរៀបចំច្បាប់ និងបទដ្ឋានគតិយុត្តដើម្បីធានាថាក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលទូទាំងពិភពលោកអនុវត្តសកម្មភាពទាន់ពេលវេលា និងមានការទទួលខុសត្រូវចំពោះមុខរដ្ឋាភិបាលក្នុងការគោរពសិទ្ធិមនុស្ស ជាពិសេសនោះគឺសិទ្ធិកុមារ។ ក្នុងន័យនេះ ពួកគេត្រូវទទួលខុសត្រូវ និងផ្តល់សំណង បើផលិតផលឬសេវាមានផលប៉ះពាល់ជាអវិជ្ជមាន ដោយសារតែគោលបំណងបង្កើនចំណូលដោយមិនគិតពីសិទ្ធិទទួលបានសុវត្ថិភាព និងសុខុមាលភាពរបស់អ្នកប្រើប្រាស់។ និន្នាការនេះក៏ដើម្បីកាត់បន្ថយ និងបង្កើនតម្លាភាពនៃការប្រើទិន្នន័យរបស់អ្នកប្រើប្រាស់ ការដាក់ពិន័យ ទណ្ឌកម្ម និងសំណងផ្លូវច្បាប់ផ្សេងៗនៅពេលមានការបំពានសិទ្ធិ និងមិនអនុវត្តច្បាប់។

ជាទូទៅការការពារសិទ្ធិរបស់អ្នកប្រើប្រាស់សេវាឬផលិតផលឌីជីថល ត្រូវបានបង្ហាញនៅក្នុងច្បាប់នានាដែលមានជាធរមាន។ សិទ្ធិរបស់អ្នកប្រើប្រាស់សេវាទូរគមនាគមន៍ ការទទួលបានឯកជនភាព សន្តិសុខ និងសុវត្ថិភាពត្រូវបានការពារក្នុងមាត្រា ៦៥ នៃច្បាប់ទូរគមនាគមន៍(២០១៥)។ ច្បាប់នេះក៏បានកំណត់អំពីសិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការចូលរួមពិគ្រោះយោបល់នានា នៅក្នុងដំណើរការអភិវឌ្ឍគោលនយោបាយដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍។ កាតព្វកិច្ចរបស់ប្រតិបត្តិករក្នុងការធានាសិទ្ធិនេះមានចែងច្បាស់នៅក្នុងអនុក្រឹត្យលេខ១១០ ស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មាត្រា២៧ ដែលបញ្ជាក់ច្បាស់អំពីការទទួលខុសត្រូវរបស់ក្រុមហ៊ុនផ្តល់សេវានិងផលិតផលបច្ចេកវិទ្យាដូចខាងក្រោម៖

ក ការពារព័ត៌មានឯកជន សន្តិសុខ និងសុវត្ថិភាពនៃការប្រើប្រាស់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ខ បំពេញប្រតិបត្តិការស្របតាមគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកបដោយប្រសិទ្ធភាព

គ ចូលរួមអនុវត្តតាមការណែនាំរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ឃ ហាមបើកអាជីវកម្មដែលមានលក្ខណៈខុសច្បាប់

ង បំពេញកាតព្វកិច្ចផ្សេងទៀតតាមការកំណត់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំក្រោមវិសាលភាពនៃចំណុច "ង" ខាងលើដែលបានបញ្ជាក់យ៉ាងច្បាស់ថាប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនទាំងឡាយដែលផ្តល់សេវាឬផលិតផលក្នុងវិស័យឌីជីថលត្រូវអនុវត្តទៅតាមកាតព្វកិច្ចផ្សេងទៀតដែលបានកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ស្របគ្នានេះ ក៏មានការទទួលស្គាល់ថា យន្តការសម្របសម្រួលក្នុងកិច្ចការពារកុមារលើប្រព័ន្ធអនឡាញប្រកបដោយប្រសិទ្ធភាព និងសមភាព ត្រូវមានទាំងបទដ្ឋានគតិយុត្តជាតិ និងបទបញ្ញត្តិផ្ទៃក្នុងរបស់ក្រុមហ៊ុនបច្ចេកវិទ្យា ដែលគោរពនិងគិតគូរពីការបញ្ចូលសិទ្ធិកុមារយ៉ាងពេញលេញក្នុងលំហាឌីជីថល។ ការអនុវត្តគោលការណ៍នេះ គឺជាការតាំងចិត្តរួមរបស់ក្រុមហ៊ុនបច្ចេកវិទ្យាដែលមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ក្នុងការគិតគូរទុកជាមុននូវបញ្ហាសុវត្ថិភាព និងសុខុមាលភាពរបស់កុមារលើប្រព័ន្ធអនឡាញ។ គោលការណ៍នេះបំពេញបន្ថែមឱ្យច្បាប់ និងបទដ្ឋានគតិយុត្តដែលមានជាធរមាននៅកម្ពុជា ហើយឆ្លើយតបទៅនឹងកាតព្វកិច្ចថ្នាក់តំបន់និងសកល ក្នុងការត្រួតពិនិត្យបច្ចេកវិទ្យាឌីជីថលលើការគោរពសិទ្ធិកុមារ កាតព្វកិច្ច និងនីតិវិធីនៃប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[៤] គោលការណ៍ណែនាំនេះ មានការគិតគូរពីការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទនិងការរំលោភបំពានកុមារលើប្រព័ន្ធអនឡាញ និងអំពើហិង្សាផ្សេងទៀតដែលប្រើប្រាស់បច្ចេកវិទ្យាដោយមានបញ្ចូលទាំងបទប្បញ្ញត្តិដើម្បីធានាសិទ្ធិសមូហភាពរបស់កុមារក្នុងបរិស្ថានឌីជីថល និងធានាថាក្រុមហ៊ុនបច្ចេកវិទ្យាចាត់វិធានការទាន់ពេលវេលា និងមានតម្លាភាពក្នុងការឆ្លើយតបចំពោះបញ្ហានេះ។ ទិដ្ឋភាពផ្សេងទៀតក្នុងគោលការណ៍ណែនាំ មានចែងក្នុងច្បាប់ និងគោលនយោបាយជាធរមាន ហើយមានសារៈសំខាន់សម្រាប់ចងកាតព្វកិច្ចវិស័យបច្ចេកវិទ្យាឌីជីថលក្នុងស្រុក និងក្រុមហ៊ុនសកលដែលមានប្រតិបត្តិការក្នុងប្រទេសកម្ពុជា ទៅនឹងវិធីសាស្ត្ររួមមួយក្នុងការការពារកុមារលើប្រព័ន្ធអនឡាញ ដើម្បីសម្រេចបាននូវគោលបំណងរួមមួយគឺពិភពឌីជីថលប្រកបដោយសុវត្ថិភាពសម្រាប់កុមារ។

[៤] ច្បាប់ស្តីអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចឆ្នាំ ២០១៩

# ២. ជំហានសំខាន់ៗដែលក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលត្រូវអនុវត្តនៅកម្ពុជា



ទោះបីជាយន្តការទាំងនេះមានសារៈសំខាន់សម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលអនុវត្តក៏ដោយ ជំហានជាដំបូងមួយចំនួនអាចនឹងមានការលំបាកចំពោះក្រុមហ៊ុនខ្នាតតូច ដែលមានចំនួននិយោជិតតិច ប្រាក់ចំណូល និងធនធានមានកម្រិត។ ផ្នែកនីមួយៗនៃសកម្មភាព ដំណើរការ និងយន្តការទាំងនេះអាចបត់បែនទៅតាមទំហំ និងធនធានរបស់ក្រុមហ៊ុននីមួយៗ។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នឹងដើរតួនាទីក្នុងការផ្តល់ការគាំទ្របច្ចេកទេសដល់ក្រុមហ៊ុនខ្នាតតូច និងធុរកិច្ចថ្មីឌីជីថល អំពីការយល់ដឹងស្តីពីសិទ្ធិកុមារ និងទំនួលខុសត្រូវលើកិច្ចការពារកុមារ។ ប៉ុន្តែទំហំរបស់ក្រុមហ៊ុនមិនគួរជាហេតុផលក្នុងការមិនអនុវត្តនូវគោលការណ៍នេះទេ។ ឧបករណ៍មានប្រយោជន៍សម្រាប់ក្រុមហ៊ុនខ្នាតតូច សហគ្រាសធុនតូច និងមធ្យម និងធុរកិច្ចថ្មីឌីជីថល ដូចជាគោលការណ៍រចនាប្រកបដោយសុវត្ថិភាព (Safety-by-design) និងការវាយតម្លៃផលប៉ះពាល់ជាដើម អាចរកបានតាមរយៈការិយាល័យគណៈកម្មាធិការសុវត្ថិភាពអ៊ីនធឺណិតអូស្ត្រាលី (Australian eSafety Commissioner Office)។ បទប្បញ្ញត្តិនិងការត្រួតពិនិត្យគោលការណ៍ទាំងនេះត្រូវពិចារណាទៅតាមទំហំនិងសមត្ថភាពក្រុមហ៊ុន រីឯវិសាលភាពនៃការវាយតម្លៃអាចមានទំហំខុសគ្នាដែរ។

តម្លាភាពគឺជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការបង្កើនទំនុកចិត្តនិងការជឿជាក់របស់សារណជនទៅលើសេវាឬផលិតផល។ ក្រុមហ៊ុនគួរតែផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំដែលមានបង្ហាញពីចំនួននៃការរាយការណ៍អំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ និងទម្រង់ផ្សេងៗទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ចំនួននៃសកម្មភាពឆ្លើយតបតាមរយៈការព្រមាន ការផ្អាកបណ្តោះអាសន្ន ការបិទគណនី និងសកម្មភាពផ្សេងទៀត និងចំនួនរបាយការណ៍បញ្ជូនបន្តទៅកាន់អាជ្ញាធរ និងរយៈពេលអន្តរាគមន៍។[៥] របាយការណ៍ទាំងនេះ អាចយកតាមបញ្ជីត្រួតពិនិត្យលើអនុលោមភាព សូចនាករ និងវង្វាស់សំខាន់ៗដែលមានភ្ជាប់ក្នុងគោលការណ៍ណែនាំ។

## ២.១ ការវាយតម្លៃផលប៉ះពាល់សិទ្ធិកុមារ (CRIA)

**ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលត្រូវវាយតម្លៃផលប៉ះពាល់ដែលអាចកើតឡើងពីសេវាឬផលិតផលរបស់ខ្លួនចាប់តាំងពីដំណាក់កាលបំផុសគំនិតនិងរចនារហូតដល់ការដាក់ដំណើរការនៅលើទីផ្សារ។** យន្តការវាយតម្លៃផលប៉ះពាល់សិទ្ធិកុមារនេះមិនត្រឹមតែពិនិត្យទៅលើសិទ្ធិកុមារក្នុងការទទួលបានសុវត្ថិភាពក្នុងបរិស្ថានឌីជីថលប៉ុណ្ណោះទេតែថែមទាំងអាចប្រើប្រាស់សម្រាប់វាយតម្លៃផលប៉ះពាល់ដែលអាចកើតមានទៅលើសិទ្ធិសមូហភាពរបស់កុមារដែរ។ *ការវាយតម្លៃនេះ គួរតែពិនិត្យមើលលើផលប៉ះពាល់ធំៗនៃសេវានិងផលិតផលទាំងអស់របស់ក្រុមហ៊ុននីមួយៗ លើសិទ្ធិសមូហភាពនិងសិទ្ធិស្មើភាពគ្នារបស់កុមារ។ លទ្ធផលនៃការវាយតម្លៃ គួរតែជាមូលដ្ឋានក្នុងការដាក់ចេញនូវវិធានការការពារបន្តបន្ទាប់។* អង្គការយូនីសេហ្វបានសហការណ៍ជាមួយប្រតិបត្តិករទូរគមនាគមន៍ជាច្រើននៅលើពិភពលោកដើម្បីបង្កើតនូវឧបករណ៍វាយតម្លៃផលប៉ះពាល់សិទ្ធិនេះសម្រាប់ក្រុមហ៊ុនទូរស័ព្ទចល័ត[៦]។ ទោះបីឯកសារនេះ ត្រូវបានរៀបចំសម្រាប់ប្រតិបត្តិករទូរស័ព្ទចល័តក៏ដោយ ក៏អាចប្រើប្រាស់បានដោយអាជីវកម្មផ្សេងៗក្នុងវិស័យបច្ចេកវិទ្យាឌីជីថលទាំងមូលដែរ។ ក្រុមហ៊ុនដែលបានវាយតម្លៃផលប៉ះពាល់សិទ្ធិកុមារហើយ មិនចាំបាច់ធ្វើការវាយតម្លៃឡើងវិញនោះទេ។

[៥] Adapted from Tech Coalition, Trust: Voluntary Framework for Industry Transparency

[៦] UNICEF, 2021, MO-CRIA: Child Rights Impact Self-assessment Tool for Mobile Operators, UNICEF, New York).

## ២.២ ការបង្កើត និងអនុវត្តនីតិវិធីផ្ទៃក្នុង

**ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលត្រូវបង្កើតនិងអនុវត្តគោលនយោបាយនិងនីតិវិធីផ្ទៃក្នុង ដើម្បីការពារសុវត្ថិភាពកុមារ។** គោលនយោបាយ និងនីតិវិធីទាំងនេះ ត្រូវអនុវត្តគ្រប់ផ្នែកទាំងអស់របស់ក្រុមហ៊ុន ក្នុងចេតនាការពារនិយោជិតនិងកុមារពីគ្រោះថ្នាក់ រួមទាំងការត្រួតពិនិត្យដោយប្រុងប្រយ័ត្នចំពោះនិយោជិតណាដែលជួបប្រទះរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ។ គោលនយោបាយនេះគួរតែមានចែងអំពីបែបបទនៃការប្រព្រឹត្តិ និងការគោរពសិទ្ធិសម្ងាត់កុមាររបស់គណៈគ្រប់គ្រង និងនិយោជិតទាំងអស់ ព្រមទាំងការរចនាផលិតផល និងសេវា។ ទន្ទឹមនឹងនេះ ក៏ត្រូវចែងអំពីផលវិបាកដែលកើតចេញពីការបំពានគោលនយោបាយ និងនីតិវិធីផ្ទៃក្នុង ហើយត្រូវចែងអំពីរបៀបរាយការណ៍ជាសម្ងាត់អំពីការបំពាន ឬការសង្ស័យករណីបំពានណាមួយ។ យន្តការទាំងនេះត្រូវបញ្ជ្រាបចូលជាផ្លូវការទៅក្នុងគោលនយោបាយនិងនិតិវិធីផ្ទៃក្នុងរបស់ក្រុមហ៊ុន។

## ២.៣ ការអនុវត្តគោលការណ៍រចនាប្រកបដោយសុវត្ថិភាព

**ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ត្រូវអនុវត្តគោលការណ៍រចនាប្រកបដោយសុវត្ថិភាព (Safety-by-design) និងគោលការណ៍រចនាប្រកបដោយឯកជនភាព (Privacy-by-design)។** ការអនុវត្តទាំងនេះគឺដើម្បីធានាថា មានការវាយតម្លៃពីផលប៉ះពាល់នៃសេវា និងផលិតផលថ្មីៗរបស់ខ្លួនទៅលើសុវត្ថិភាពរបស់កុមារ ចាប់តាំងពីដំណាក់កាលបំផុសគំនិត និងរចនាផលិតផល ឬសេវាដែលអាចធ្វើឱ្យដំណើរការអភិវឌ្ឍបន្តទៀត មានបញ្ចូលយន្តការសុវត្ថិភាពសមស្រប និងអាចសម្រួលកែប្រែបាននៅពេលក្រោយ។ ការអនុវត្តនេះដូចគ្នាជាមួយនឹងគោលការណ៍រចនាប្រកបដោយឯកជនភាព ដែលសំដៅទៅលើវិធីសាស្រ្តក្នុងការរចនាប្រព័ន្ធប្រតិបត្តិការមូលដ្ឋានដែលធានាអំពីឯកជនភាព និងការការពារទិន្នន័យកុមារ។ *គួរកត់សម្គាល់ថា គោលការណ៍ខាងលើនេះក៏គួរប្រើដើម្បីវាយតម្លៃផលិតផលនិងសេវាកម្មដែលមានស្រាប់ ការរចនាផលិតផល និងសេវាកម្មឡើងវិញ និងការធ្វើបច្ចុប្បន្នភាពដើម្បីធានាសុវត្ថិភាព និងឯកជនភាព។*

ការរចនាប្រកបដោយសុវត្ថិភាព (Safety-by-design) គឺជាវិធីសាស្រ្តក្នុងការរចនាផលិតផល និង សេវាដែលគិតគូរអំពីសុវត្ថិភាពរបស់អ្នកប្រើប្រាស់ជាចម្បង។ នេះមានសេចក្តីថាក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលអាចកាត់បន្ថយហានិភ័យលើប្រព័ន្ធអនឡាញ តាមរយៈការគិតទុកជាមុន ការតាមចាប់ និងការលុបបំបាត់គ្រោះថ្នាក់លើប្រព័ន្ធអនឡាញមុននឹងវាអាចកើតឡើងបាន។[៧] ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលគួរប្រើប្រាស់គោលការណ៍ការរចនាប្រកបដោយសុវត្ថិភាពទៅលើផលិតផល និងសេវាថ្មីៗទាំងអស់របស់ខ្លួន។ មានឧទាហរណ៍ជាច្រើនស្តីអំពីការប្រើប្រាស់គោលការណ៍រចនាប្រកបដោយសុវត្ថិភាព ដោយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅទូទាំងពិភពលោក ហើយដែលអាចផ្តល់ជាការចង្អុលបង្ហាញអំពីការបញ្ជ្រាបគោលការណ៍នេះទៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន។ ឧទាហរណ៍នេះអាចរកបានក្នុងឧបករណ៍**វាយតម្លៃអំពីការរចនាប្រកបដោយសុវត្ថិភាព**របស់គណៈកម្មាធិការសុវត្ថិភាពអ៊ីនធឺណិតរបស់អូស្រ្តាលី។ វាមានភាពចាំបាច់ក្នុងការទទួលយកបទពិសោធន៍ និងការចូលរួមរបស់

[៧] https://www.esafety.gov.au/industry/safety-by-design

កុមារដើម្បីបង្កើតគោលការណ៍ការរចនាប្រកបដោយសុវត្ថិភាព ហើយធានាថាវិធីសាស្ត្រទាំងនោះឆ្លុះបញ្ចាំងអំពីតម្រូវការ និងការព្រួយបារម្ភរបស់កុមារនៅកម្ពុជា។

**ក្រុមហ៊ុនត្រូវប្រើប្រាស់សេចក្តីណែនាំស្តីពីការលូតលាស់ និងការវិវត្តសមត្ថភាពកុមារ ដើម្បីធានាការរចនាស្របតាមអាយុ (Age-appropriate design) សម្រាប់អតិថិជនគោលដៅ (សូមមើលក្នុងឧបសម្ព័ន្ធ)។** ការរចនាស្របតាមអាយុសំដៅទៅលើការគិតគូរអំពីអាយុអ្នកប្រើប្រាស់សេវាឬផលិតផល និងដំណាក់កាលនៃការលូតលាស់ និងការវិវត្តសមត្ថភាពកុមារ ទៅក្នុងដំណើរការរចនានិងការបង្កើតនូវសេវាឬផលិតផលថ្មី។ ការធ្វើបែបនេះគឺដើម្បីធានាថា ការចាប់ផ្តើមបង្កើតផលិតផលណាមួយ បានពិចារណាអំពីផលប៉ះពាល់ចំពោះកុមារដែលមានវ័យខុសៗគ្នា។ ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល គួរតែគិតគូរអំពីអាយុអតិថិជនជាមួយនឹងតម្រូវការ និងដំណាក់កាលលូតលាស់របស់កុមារដោយគ្រាន់តែប្រើប្រាស់នូវកូដរចនា (Design Codes) សមស្របតាមអាយុកុមារក្នុងការរចនាសេវាឬផលិតផលរបស់ខ្លួន។ ការគិតគូរនេះគួរតែធ្វើឡើងទាំងចំពោះសេវាឬផលិតផលទាំងឡាយផ្សេងទៀត ទោះមិនសម្រាប់ឱ្យកុមារប្រើប្រាស់ ឬត្រូវបានប្រើប្រាស់ដោយកុមារក៏ដោយ។ ហេតុនេះវិធានការការពារហានិភ័យសមរម្យគួរតែដាក់ចេញ ដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតឡើងនៅពេលកុមារប្រើប្រាស់សេវាឬផលិតផលទាំងនេះ។

**ការគិតគូរនេះមានរួមបញ្ចូលទាំងការប្រមូល ការផ្ទុក និងដំណើរការទិន្នន័យកុមារក្នុងអំឡុងពេលដែលពួកគេប្រើប្រាស់សេវាឬផលិតផល។** ក្រុមហ៊ុនត្រូវគិតគូរជាពិសេសទៅលើការប្រមូល និងដំណើរការទិន្នន័យកុមារក្នុងគោលបំណងធានាការពារសិទ្ធិរបស់ពួកគេ។ វិធានការដែលត្រូវអនុវត្តដើម្បីធានាពីការការពារសិទ្ធិកុមាររួមមានការកាត់បន្ថយការប្រមូលទិន្នន័យកុមារជាអប្បបរមា (Data Minimization) ការកំណត់ព្រំដែននៃការប្រមូលទិន្នន័យ (Purpose Limitation) ការកំណត់រយៈពេលនៃការរក្សាទុកទិន្នន័យ (Storage Limitation) និងសន្តិសុខទិន្នន័យ (Data security)។ គំរូនៃកូដរចនាស្របតាមអាយុអាចរកបានជាឧទាហរណ៍នៅក្នុង **កូដរចនាស្របតាមអាយុរបស់ប្រទេសអង់គ្លេស**។ សម្រាប់ក្រុមហ៊ុនខ្នាតតូចនិងមធ្យម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចផ្តល់ការណែនាំនិងការគាំទ្រនៅក្នុងការវាយតម្លៃប្រសិនបើមានតម្រូវការ។

## ២.៤ ការគាំទ្រនិងលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពលើប្រព័ន្ធអនឡាញ

**ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ត្រូវជួយគាំទ្រដល់កុមារ ក្រុមគ្រួសារ និងគ្រូបង្រៀន ក្នុងការអភិវឌ្ឍជំនាញឌីជីថល ដែលអាចការពារសុវត្ថិភាពរបស់ពួកគេលើប្រព័ន្ធអនឡាញបាន។** ក្រៅពីនេះមានជំនាញផ្សេងទៀតដូចជាជំនាញគ្រប់គ្រងផ្លូវអារម្មណ៍និងបំណិនជីវិតដែលអាចជួយជំរុញការសម្រេចប្រកបដោយសុវត្ថិភាពលើប្រព័ន្ធអនឡាញ។ ការផ្តួចផ្តើមទាំងនេះគួរគិតគូររួមបញ្ចូលពីហានិភ័យដែលកុមារអាចទទួលបានពីមិត្តភក្តិ មនុស្សជិតស្និទ្ធរបស់ពួកគេ ជាជាងផ្តោតតែទៅលើ "គ្រោះថ្នាក់ពីជនមិនស្គាល់"។ ការផ្តួចផ្តើមទាំងនេះក៏គួរគិតគូរអំពីការអប់រំទប់ស្កាត់សមស្របទៅនឹងអាយុកុមារ ការជួយដល់ឪពុកម្តាយ និងអាណាព្យាបាលក្នុងការប្រើប្រាស់វិធីសាស្ត្រសន្ទនាដោយបើកចំហ និងផ្តល់ការគាំទ្រដល់កូនរបស់ពួកគេ ជាជាងប្រើវិធីសាស្ត្រស្តីបន្ទោស ឬដាក់ទណ្ឌកម្មនៅពេលកុមារទទួលរងគ្រោះ។ កិច្ចការនេះអាចធ្វើទៅបានតាមរយៈការជួយគាំទ្រដល់កម្មវិធីផ្លាស់ប្តូរឥរិយាបថសង្គមដែលកំពុងអនុវត្តនៅតាមសាលារៀន និងសហគមន៍ ជាជាងការផ្តល់នូវការអប់រំ និងការលើកកម្ពស់ការយល់ដឹង

ដាច់ដោយឡែក។ ភស្តុតាងថ្មីអំពីប្រសិទ្ធភាពនៃកិច្ចការពារអំពើហឹង្សាតាមប្រព័ន្ធអនឡាញ និងការអប់រំផ្សេងៗ អាចរកឃើញក្នុងតំណភ្ជាប់នេះ https://www.who.int/publications/i/item/9789240062061។ សកម្មភាពទាំងនេះមិនអាចដកការទទួលខុសត្រូវ ឬបន្ទុករបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ពីការធានាសុវត្ថិភាព និងភាពសមស្របតាមអាយុនៃផលិតផល និងសេវាកម្មរបស់គេទេ។ ហើយក៏មិនអាចយកសកម្មភាពនេះ បន្ទោសទៅលើជនរងគ្រោះថាមិនបានអនុវត្តសកម្មភាពត្រឹមត្រូវនៅពេលគេជួបការកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ និងទម្រង់នៃហានិភ័យផ្សេងទៀតឡើយ។

ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលមានតួនាទីសំខាន់ក្នុងការជួយគាំទ្រការបញ្ជាក់ភស្តុតាង។ កន្លងមកទិន្នន័យមូលដ្ឋានពាក់ព័ន្ធការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) និងអំពើហិង្សាដែលប្រើបច្ចេកវិទ្យានៅកម្ពុជាមាននៅក្នុងការស្រាវជ្រាវការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (Disrupting Harms Study Cambodia)។[៨] ទោះបីជាយ៉ាងនេះក៏ដោយ មានតម្រូវការភស្តុតាងបន្ថែមទៀតជាច្រើន ដូចជាភស្តុតាងស្តីអំពីអន្តរាគមន៍ជាក់លាក់ និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំ និងលើកកម្ពស់ការយល់ដឹងនានា។ ស្របពេលដែលបច្ចេកវិទ្យាថ្មីៗត្រូវបានប្រើប្រាស់ បច្ចេកវិទ្យាក្នុងវិស័យអប់រំកំពុងត្រូវបានពង្រីក ហើយបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សា (Machine Learning) បានជ្រាបចូលក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា ការសិក្សាស្រាវជ្រាវអំពីហានិភ័យ គ្រោះថ្នាក់ ឱកាស និងផលប្រយោជន៍ដែលកើតឡើងពីបច្ចេកវិទ្យាទាំងនេះគួរធ្វើឡើងបន្ថែមទៀត ។ ក្រុមហ៊ុនឧស្សាហកម្មបច្ចេកវិទ្យាឌីជីថល គឺជាស្នូលនៃដំណើរការនេះ។

## ២.៥ ការបង្កើតបរិស្ថានសុវត្ថិភាពលើប្រព័ន្ធអនឡាញ

ក្រៅពីការអនុវត្តនូវគោលការណ៍រចនាប្រកបដោយសុវត្ថិភាពនិងឯកជនភាព និងធានាបរិស្ថានប្រតិបត្តិការ និងដំណើរការដោយផ្តោតលើសិទ្ធិកុមារ ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលអាចអនុវត្តជំហានបន្ថែម ដូចខាងក្រោម ដើម្បីបង្កើតបរិស្ថានសុវត្ថិភាពលើប្រព័ន្ធអនឡាញសម្រាប់កុមារ។ ជំហានទាំងនោះមានដូចជា៖

- **មុខងារគ្រប់គ្រងដោយឪពុកម្តាយ (Parental Controls)** ក្នុងករណីដែលក្រុមហ៊ុនផ្តល់មុខងារគ្រប់គ្រងដោយឪពុកម្តាយ ពួកគេគួរមានការណែនាំច្បាស់លាស់អំពីរបៀបនៃការប្រើប្រាស់ និងដែនកំណត់នៃមុខងារទាំងនោះ។ ក្រុមហ៊ុនគួរបញ្ជាក់ឱ្យច្បាស់ថាមុខងារគ្រប់គ្រងដោយឪពុកម្តាយ មិនសូវមានប្រសិទ្ធភាពសម្រាប់កុមារវ័យជំទង់នោះទេ ដោយសារតែកុមារវ័យជំទង់ឆាប់ចាប់បាននូវជំនាញបច្ចេកទេសដើម្បីគេចវេសពីមុខងារគ្រប់គ្រងរបស់ឪពុកម្តាយ។ ក្រុមហ៊ុនក៏គួរតែបញ្ជាក់ឱ្យបានច្បាស់ថាមុខងារគ្រប់គ្រងដោយឪពុកម្តាយ ពេលខ្លះអាចរាំងស្ទះការអភិវឌ្ឍជំនាញរបស់កុមារ ការចាប់ឱកាស និងអត្ថប្រយោជន៍ដែលកុមារអាចទទួលបាននៅលើប្រព័ន្ធអនឡាញ។ ដូច្នេះមុខងារនេះគួរតែត្រូវបានប្រើប្រាស់ដោយសមស្របតាមការលូតលាស់របស់កុមារ។

---

[៨] Kardefelt Winther, Daniel (2022). Disrupting Harm in Cambodia: Evidence on online child sexual exploitation and abuse, Innocenti Research Report

- ក្រុមហ៊ុនគួរតែផ្តល់សេវាកំណត់ឯកជនភាពនិងសុវត្ថិភាព (Opt-out services) ដោយស្វ័យប្រវត្តិ ងាយស្រួល និងផ្សព្វផ្សាយអំពីសេវាកម្មនេះឱ្យបានទូលំទូលាយ។ តាមរយៈការជ្រើសរើសសេវាកម្មនេះ គណនី និងព័ត៌មានទំនាក់ទំនងរបស់កុមារនឹងត្រូវបានកំណត់ជាឯកជន នៅពេលពួកគេទាញយកកម្មវិធីទូរស័ព្ទដៃឬកម្មវិធីសុសវែរថ្មីៗ។
- ក្នុងករណីដែលមាតិកា ផលិតផល និងសេវាអនឡាញ ត្រូវបានរចនាឡើងជាពិសេសសម្រាប់កុមារ ក្រុមហ៊ុនគួរតែដាក់ចេញនូវ "លក្ខខណ្ឌនៃការប្រើប្រាស់" ច្បាស់លាស់ និងធានាមិនឱ្យមានការបំពានទៅលើលក្ខខណ្ឌទាំងអស់នោះ ។
- ក្រុមហ៊ុនត្រូវធានាថា កុមារអាចរកឃើញនូវវិធីសម្រាប់កំណត់ឯកជនភាព និងរបៀបការពារទិន្នន័យផ្ទាល់ខ្លួន និងព័ត៌មានច្បាស់លាស់អំពីការប្រមូលទិន្នន័យឯកជនភាព ហេតុផល និងតើទិន្នន័យឯកជនរបស់គេត្រូវយកទៅចែករំលែកជាមួយអ្នកផ្សេងណាខ្លះ។ ព័ត៌មានទាំងនេះគួរមានបង្ហាញច្បាស់លាស់នៅលើកម្មវិធីទូរស័ព្ទដៃ គេហទំព័រ និងកម្មវិធីផ្សេងៗ ក្នុងលក្ខណៈងាយស្រួល ងាយយល់ ងាយធ្វើតាមទាំងចំពោះកុមារទូទៅនិងកុមារមានពិការភាព។

## ២.៦. ការទប់ស្កាត់ និងការឆ្លើយតបទៅនឹងរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM)

ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលមានតួនាទីសំខាន់ក្នុងការទប់ស្កាត់ និងការឆ្លើយតបទៅនឹង រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ តាមរយៈការអនុវត្តនូវគោលការណ៍រចនាប្រកបដោយសុវត្ថិភាព។ ប៉ុន្តែនីតិវិធីក្នុងការជូនដំណឹង និងដកចេញ (Notice and Takedown procedure) មានភាពចាំបាច់ក្នុងការបង្កើតប្រព័ន្ធទប់ស្កាត់ និងឆ្លើយតបរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារប្រកបដោយប្រសិទ្ធភាព។ ក្រុមហ៊ុននីមួយៗគួរតែអនុវត្តជំហានដូចខាងក្រោម ដើម្បីដោះស្រាយបញ្ហារូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ និងទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។

- ក្រុមហ៊ុនត្រូវដាក់ចេញឱ្យបានច្បាស់នូវ "លក្ខខណ្ឌនៃការប្រើប្រាស់" ដែលហាមប្រាមមាតិកា ឬសកម្មភាពទាំងឡាយណាដែលអាចបង្កើតឱ្យមានរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ ឬការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។ លក្ខខណ្ឌទាំងនេះ គួរបង្ហាញឱ្យបានច្បាស់នៅលើគេហទំព័រ និងកម្មវិធីសុសវែររបស់ខ្លួន ហើយមានភាពងាយស្រួលស្វែងយល់ចំពោះអ្នកប្រើប្រាស់ទាំងអស់ ទោះជាពួកគេមិនមានជំនាញច្បាប់ ឬឌីជីថលក៏ដោយ។ ចំពោះផលិតផលទាំងឡាយណាដែលរៀបចំឡើងសម្រាប់កុមារ ឬអាចត្រូវកុមារប្រើប្រាស់ដោយប្រការណាមួយ "**លក្ខខណ្ឌនៃការប្រើប្រាស់**" គួរតែបង្ហាញឡើងតាមវិធីមួយដែលកុមារងាយស្រួលយល់។ លក្ខខណ្ឌទាំងនេះ គួរគិតគូរបង្កភាពងាយស្រួលដល់កុមារមានពិការភាពដែរ។ ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលគួរប្រកាសអំពីការតាំងចិត្តក្នុងការទប់ស្កាត់និងឆ្លើយតបចំពោះរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ នៅពេលចុះបញ្ជីឬស្នើសុំអាជ្ញាបណ្ណជាមួយក្រសួងពាណិជ្ជកម្ម ឬអាជ្ញាធរពាក់ព័ន្ធ។

- **ក្រុមហ៊ុនគួរបង្កើតច្រករាយការណ៍ (Reporting Portals) លើគ្រប់មាតិកាទាំងអស់នៅលើគេហទំព័រ កម្មវិធីសុសវែរ ឬថ្នាលឌីជីថលនានាដែលមាន ឬសង្ស័យថាជា រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ។** ច្រករាយការណ៍នេះគួរតែងាយស្រួលមើលឃើញ និងអាចចូលប្រើប្រាស់បានសម្រាប់ទាំងមនុស្សពេញវ័យ និងកុមារ។ ការរាយការណ៍ដែលធ្វើឡើងនៅលើថ្នាលនេះ គួរតែបញ្ជូនទៅភ្នាក់ងារទទួលបន្ទុកកិច្ចការនេះផ្ទាល់ ឬទៅផ្នែកបច្ចេកទេសរបស់ក្រុមហ៊ុន ជាជាងទៅកាន់ផ្នែកបម្រើសេវាអតិថិជនទូទៅ។ ផ្នែកទទួលបន្ទុកការងាររូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារនេះគួរតែស្ថិតនៅក្នុងអង្គភាពតែមួយជាមួយនឹងផ្នែកសន្តិសុខអ៊ីនធឺណិតរបស់ក្រុមហ៊ុន។ ច្រករាយការណ៍គួរតែស្នើសុំព័ត៌មានអ្នករាយការណ៍តិចតួចបំផុត ដើម្បីជួយនៅក្នុងការដំណើរការត្រួតពិនិត្យមាតិកា។ ព័ត៌មានទាំងនោះរួមបញ្ចូល អាសយដ្ឋាន (URL) ឬតំណភ្ជាប់ទៅកាន់មាតិកា លក្ខណៈនៃរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ កាលបរិច្ឆេទ និងម៉ោង ព្រមទាំងផ្តល់ជម្រើសសម្រាប់ការផ្តល់ឈ្មោះ និងលេខទំនាក់ទំនង។ ការផ្តល់ឈ្មោះ និងលេខទំនាក់ទំនងនេះមិនមែនជាតម្រូវចាំបាច់ទេ ព្រោះអ្នកប្រើប្រាស់អាចជ្រើសរើសរាយការណ៍ដោយអនាមិកបាន។ ច្រករាយការណ៍គួរអាចចូលប្រើប្រាស់បានដោយងាយស្រួល ទាំងកុមារ ទាំងអ្នកប្រើប្រាស់គ្រប់វ័យ (សូមមើលក្នុងប្រអប់)។ ច្រករាយការណ៍ ត្រូវមានកំណត់ពីពេលវេលាច្បាស់លាស់ក្នុងការចាត់វិធានការ និងឆ្លើយតបនៅពេលមានការរាយការណ៍។

  ផ្ទាំងរាយការណ៍(Reporting Interface) នៅលើគេហទំព័រ និងផលិតផលអាចតភ្ជាប់ដោយផ្ទាល់ទៅនឹងច្រករាយការណ៍បន្ទាន់អំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារដែលមានការទទួលស្គាល់ និងមានភាពជាដៃគូផ្លូវការដូចជា មូលនិធិឃ្លាំមើលប្រព័ន្ធអ៊ីនធឺណិត(IWF) ឬ មជ្ឈមណ្ឌលជាតិសម្រាប់កុមារបាត់ខ្លួននិងការកេងប្រវ័ញ្ច(NCMEC)។ ការរាយការណ៍មិនគួរជាបន្ទុករបស់ជនរងគ្រោះតែទោះជាយ៉ាងនេះ ក្រុមហ៊ុនគួរបង្កើតជម្រើសងាយស្រួលសម្រាប់កុមារ និងអ្នកជុំវិញពួកគេដូចជាគ្រូបង្រៀនជាដើម។ល។ គួរកត់សម្គាល់ថាទោះជាក្រុមហ៊ុនមានទំហំផ្សេងៗគ្នាក៏ដោយ រាល់សេវា ឬផលិតផលទាំងអស់គួរមាននូវជម្រើសរាយការណ៍ពីការរំលោភបំពាន។

- **ក្រុមហ៊ុនគួរបង្កើតទំនាក់ទំនង ជាមួយភ្នាក់ងារ និងដៃគូអន្តរជាតិ រួមទាំងស្ថាប័នដែលមាន ឬអាចចូលប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរូបភាពសម្ភាររំលោភបំពានផ្លូវភេទកុមារ ដូចជាមូលនិធិឃ្លាំមើលប្រព័ន្ធអ៊ីនធឺណិត (IWF) ឬមជ្ឈមណ្ឌលជាតិសម្រាប់កុមារបាត់ខ្លួន និងការកេងប្រវ័ញ្ច (NCMEC) ជាដើម។** ស្ថាប័នទាំងនេះជាអ្នកជួយទ្រទ្រង់ច្រករាយការណ៍បន្ទាន់អំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ តាមរយៈការចុះអនុស្សរណៈនៃការយោគយល់ និងកិច្ចព្រមព្រៀងផ្លូវការ។ ជាទូទៅ រូបភាពទាំងអស់ ត្រូវបានរាយការណ៍តាមច្រករាយការណ៍បន្ទាន់ទៅកាន់នគរបាលអន្តរជាតិ(INTERPOL) ដែលជាអ្នកគ្រប់គ្រងរួមលើប្រព័ន្ធទិន្នន័យរូបភាពកេងប្រវ័ញ្ចផ្លូវភេទកុមារអន្តរជាតិ (ប្រព័ន្ធទិន្នន័យ ICSE)។ ប្រព័ន្ធទិន្នន័យនេះត្រូវបានប្រើប្រាស់ដោយទីភ្នាក់ងារអនុវត្តច្បាប់ទូទាំងពិភពលោករួមទាំងនគរបាលជាតិកម្ពុជាដែរ។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នឹងដើរតួជាអន្តរការីរវាងក្រុមហ៊ុន

បច្ចេកវិទ្យាឌីជីថលនៅកម្ពុជានិងប្រព័ន្ធទិន្នន័យរូបភាពកេងប្រវ័ញ្ចផ្លូវភេទកុមារអន្តរជាតិ។ ទោះជាយ៉ាងនេះ ក្រុមហ៊ុនអាចបង្កើតកិច្ចសហការផ្ទាល់ជាមួយមូលនិធិឃ្លាំមើលប្រព័ន្ធអ៊ីនធឺណិត (IWF) ឬមជ្ឈមណ្ឌលអន្តរជាតិសម្រាប់កុមារបាត់ខ្លួននិងការកេងប្រវ័ញ្ច (ICMEC) ជាដើម។

ឧបករណ៍ស្កែនរករូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារដោយស្វ័យប្រវត្តិ ឬដោយបញ្ញាសិប្បនិម្មិត មានដូចជាកម្មវិធី Microsoft DNA, Project Arachnid និងមានសុវត្ថិភាពជាងមុនក្នុងការប្រើប្រាស់ប្រព័ន្ធបញ្ញាសិប្បនិម្មិត ដើម្បីស្កែនរករូបភាពសម្ភាររំលោភបំពានផ្លូវភេទកុមារ។ ប្រព័ន្ធ និងវិធានការដែលអាចធ្វើសកម្មភាពទាន់ពេលណាមួយដើម្បីស្វែងរករូបភាពសម្ភាររំលោភបំពានផ្លូវភេទកុមារ និងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ឬទម្រង់ផ្សេងទៀតនៃមាតិកាខុសច្បាប់ គួរតែត្រូវបានប្រើប្រាស់យ៉ាងប្រុងប្រយ័ត្នជានិច្ច ដោយធានាថាសិទ្ធិឯកជនភាពត្រូវបានគោរព (United Nations Children's Fund (២០២២))។ 'ការធ្វើបទបញ្ញត្តិសម្រាប់យុគសម័យឌីជីថល៖ គោលការណ៍ណែនាំជាសកលស្តីពីការកែលម្អក្របខ័ណ្ឌនីតិបញ្ញត្តិដើម្បីការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ' យូនីសេហ្វ ញូវយ៉ក។

អនុសញ្ញាស្តីពីសិទ្ធិកុមារកត់សម្គាល់ថាការជ្រៀតជ្រែកណាមួយចំពោះសិទ្ធិឯកជនភាពរបស់កុមារគួរតែត្រូវបាន "ផ្តល់ដោយច្បាប់ដែលមានបំណងបម្រើភាពស្របច្បាប់ រក្សាគោលការណ៍នៃទិន្នន័យជាអប្បបរមា សមាមាត្រ និងរៀបចំឡើងដើម្បីរក្សាផលប្រយោជន៍ល្អបំផុតសម្រាប់កុមារ ហើយមិនត្រូវប្រឆាំងជាមួយ បទបញ្ញត្តិ គោលដៅ ឬគោលបំណងនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ' ។ អនុសាសន៍ទូទៅរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ លេខ២៥ (២០២១), កថាខណ្ឌ ៦៩។

នេះសំដៅជាទូទៅដល់គោលការណ៍នៃភាពស្របច្បាប់ ភាពចាំបាច់ និងសមាមាត្រ ។

➛ **ក្រុមហ៊ុនគួរប្រើប្រាស់ឧបករណ៍ស្កែនរករូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារដោយស្វ័យប្រវត្តិ ឬដោយបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត។** ឧបករណ៍ទាំងនោះមានដូចជាកម្មវិធី Microsoft DNA, Project Arachnid ឬ Thorn's Safer ជាដើម។ ការប្រើប្រាស់ឧបករណ៍ស្វ័យប្រវត្តិក៏គួរតែធានាថាមិនប៉ះពាល់ដល់សិទ្ធិឯកជនភាពរបស់កុមារ[៩] និងមានសង្គតិភាពជាមួយកិច្ចព្រមព្រៀងគោលបំណង និងគោលដៅរបស់អនុសញ្ញាស្តីពីសិទ្ធិកុមារ ព្រមទាំងគោរពដល់សិទ្ធិឯកជនភាពរបស់កុមារ។[១០]

[៩] អង្គការយូនីសេហ្វ ២០២២។ នីតិកម្មសម្រាប់យុគសម័យឌីជីថល៖ មគ្គុទេសក៍សកលស្តីពីការកែលម្អក្របខ័ណ្ឌច្បាប់ ដើម្បីការពារកុមារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ' អង្គការយូនីសេហ្វ ទីក្រុងញូវយ៉ក។

[១០]សេចក្តីពន្យល់ទូទៅលេខ ២៥ របស់អនុសញ្ញាស្តីពីសិទ្ធិកុមារ (ឆ្នាំ២០២១) វាក្យខណ្ឌ ៦៩។

- ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត ត្រូវបិទការចូលប្រើប្រាស់ URLs ខុសច្បាប់ទាំងឡាយណាដែលបញ្ជាក់ដោយអាជ្ញាធរកម្ពុជា អង្គភាពអនុវត្តច្បាប់អន្តរជាតិ ឬច្រករាយការណ៍បន្ទាន់ដែលមានការទទួលស្គាល់ដូចជា មូលនិធិឃ្លាំមើលប្រព័ន្ធអ៊ីនធឺណិត (IWF) ឬ មជ្ឈមណ្ឌលអន្តរជាតិការពារកុមារដែលបានបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច (ICMEC) ជាដើម។ ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត គួរប្រើប្រាស់និយមន័យ "**រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ**" ដែលមានចែងនៅក្នុងគោលការណ៍ណែនាំនេះ ឱ្យបានច្បាស់លាស់ ឱ្យមានសង្គតិភាពជាមួយនឹងគោលការណ៍ណែនាំនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្នុងការអនុវត្តពិធីសារបន្ថែម ស្តីពីការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។

  ក្រុមហ៊ុនគួរតែប្រុងប្រយ័ត្នក្នុងការបិទ URLs គឺត្រូវបិទតែ URLs ណាដែលត្រូវបានបញ្ជាក់ដោយស្ថាប័នអន្តរជាតិគ្រប់គ្រងប្រព័ន្ធទិន្នន័យ រូបភាព សម្ភារៈរំលោភបំពានផ្លូវភេទកុមារ ថាមានផ្ទុករូបភាព ឬតំណភ្ជាប់ទៅកាន់រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ។[១១] ការធ្វើបែបនេះគឺដើម្បីការពារការបិទមាតិកាព័ត៌មានស្របច្បាប់ដោយធ្វេសប្រហែស ឬដោយកំហុសបច្ចេកទេស។ ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលអាចធានាបានថាវិធានការបិទ URLs របស់ពួកគេមិនរំលោភទៅលើសិទ្ធិកុមារក្នុងការទទួលបានព័ត៌មាន គឺតាមរយៈការប្រើប្រាស់បញ្ជីខ្មៅនៃ URLs ខុសច្បាប់ ដែលទទួលបានពីស្ថាប័នដៃគូដូចជាប្រព័ន្ធទិន្នន័យ ICCAM មជ្ឈមណ្ឌល NCMEC ឬ មូលនិធិ IWF។

- ក្រុមហ៊ុនគួរបង្កើតនីតិវិធីជូនដំណឹង និងដកចេញ ដែលមានបង្ហាញពីដំណើរការ និងជំហានលម្អិតត្រូវអនុវត្តក្នុងពេលដែលទទួលបានការរាយការណ៍អំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារឬមាតិការំលោភបំពានខុសច្បាប់ផ្សេងៗទៀតពីភ្នាក់ងារអនុវត្តច្បាប់ជាតិ និងអន្តរជាតិ។ ជាទូទៅនីតិវិធីជូនដំណឹង និងដកចេញ អនុវត្តតែទៅលើរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារឬសម្ភារៈរំលោភបំពានផ្លូវភេទ ឬមាតិកាខុសច្បាប់ផ្សេងៗ ដូចមានកំណត់នៅក្នុងច្បាប់តែប៉ុណ្ណោះ។

  មាតិកាមួយចំនួនដែលក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល(ជាទូទៅក្រុមហ៊ុនបណ្តាញសង្គម) បានផ្ទុកនៅប្រទេសកម្ពុជាអាចមិនមែនជាមាតិកាខុសច្បាប់នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ប៉ុន្តែអាចជាមាតិកាខុសច្បាប់នៅក្រោមដែនយុត្តាធិការដែលក្រុមហ៊ុននោះបានចុះបញ្ជី។ URLs របស់មាតិកាទាំងនោះនឹងត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ ICCAM ដោយអ្នកវិភាគនៅច្រករាយការណ៍បន្ទាន់អំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ (ជាទូទៅ គឺ INHOPE ឬ មជ្ឈមណ្ឌល NCMEC) ហើយការជូនដំណឹងនឹងត្រូវផ្ញើដោយស្វ័យប្រវត្តិទៅកាន់ភ្នាក់ងារអនុវត្តច្បាប់ និងច្រករាយការណ៍បន្ទាន់(INHOPE HOTLINE) នៅក្នុងប្រទេសកម្ពុជា ដែលបច្ចុប្បន្នដំណើរការដោយអង្គការសកម្មភាពដើម្បីកុមារ (APLE)។ ភ្នាក់ងារអនុវត្តច្បាប់មានតួនាទីចេញនូវការជូនដំណឹងទៅកាន់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា។ ភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិអាចស្នើសុំឱ្យភ្នាក់ងារអនុវត្តច្បាប់នៅកម្ពុជាចេញនូវដីកាជូនដំណឹង និងដកចេញតាមរយៈនគរបាលអន្តរជាតិ(INTERPOL) និងនគរបាលអឺរ៉ុប(EUROPOL)។ ភ្នាក់ងារអនុវត្តច្បាប់នៅ

[១១] ឧទាហរណ៍ ទាំងប្រព័ន្ធគ្រប់គ្រងសម្ភាររំលោភបំពានផ្លូវភេទលើកុមារ របស់ IWF ឬ NCMEC ឬ ប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្អែកលើជនល្មើសរបស់ INTERPOL។

កម្ពុជាក៏អាចចេញដីកាជូនដំណឹង និងដកចេញដោយផ្អែកលើព័ត៌មានដែលទទួលបានពីសាធារណជន ឬពីក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលសកល មជ្ឈមណ្ឌល NCMEC, មូលនិធិ IWF, INHOPE, INTERPOL ឬអង្គភាពអនុវត្តច្បាប់ផ្សេងទៀត។

រាល់សំណើដកចេញ (ឬការជូនដំណឹង) ដែលមានប្រភពមកពីប្រទេសកម្ពុជា ស្តីអំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងប្រទេសកម្ពុជា ទៅកាន់ប្រព័ន្ធផ្សព្វផ្សាយសង្គមអន្តរជាតិ ឬក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ត្រូវតែចេញដោយភ្នាក់ងារអនុវត្តច្បាប់ដែលបានកំណត់នៅក្នុងប្រទេសកម្ពុជា គឺអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា។ រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ ណាមួយដែលបានរាយការណ៍តាមរយៈច្រករាយការណ៍បន្ទាន់ INHOPE (ដែលដំណើរការដោយ APLE) ក៏នឹងនាំឱ្យ INHOPE បញ្ជូនសំណើបន្តទៅកាន់អង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យាដើម្បីបញ្ជាឱ្យដកចេញ។

- **ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលអាចទទួល បាន ការរាយការណ៍អំពីមាតិកាខុសច្បាប់ ឬ មាតិកាដែលសង្ស័យថាជារូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារផ្ទុកនៅលើម៉ាស៊ីនមេ(server)របស់ខ្លួន។** ក្រុមហ៊ុនត្រូវរាយការណ៍ករណីនេះទៅកាន់ភ្នាក់ងារអនុវត្តច្បាប់កម្ពុជា(អង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា)។ ពួកគេក៏អាចរាយការណ៍ទៅកាន់ច្រករាយការណ៍បន្ទាន់ (INHOPE HOTLINE) នៅកម្ពុជា។ ច្រករាយការណ៍បន្ទាន់នេះនឹងវាយតម្លៃមាតិកា ដោយមានដំណើរការដូចបង្ហាញក្នុងរូបតាងលេខ១ ខាងក្រោម។ នៅពេលដែលទទួលបានការរាយការណ៍ដំបូង ក្រុមហ៊ុនគួរតែលុបមាតិកានោះជាបណ្តោះអាសន្ន និងរង់ចាំលទ្ធផលនៃការវាយតម្លៃ។

ក្រុមហ៊ុនបណ្តាញសង្គមសកលគឺជាអ្នកដែលចេញការជូនដំណឹង និងដកចេញច្រើនបំផុត។ ការរាយការណ៍ទាំងអស់នោះកើតចេញពីការប្រើប្រាស់ឧបករណ៍ស្កេនរករូបភាពទំនើប ដូចជាឧបករណ៍ដែលបានរៀបរាប់នៅក្នុងចំណុចខាងលើ និងការប្រើប្រាស់វិធានការត្រួតពិនិត្យ និងរាយការណ៍ផ្សេងទៀត។ ក្នុងប្រទេសកម្ពុជាក្រុមហ៊ុនទាំងអស់នេះ រាយការណ៍ផ្ទាល់ទៅកាន់ច្រករាយការណ៍បន្ទាន់ (INHOPE HOTLINE) និងអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា។ ការរាយការណ៍របស់សាធារណជននៅកម្ពុជាក៏អាចធ្វើឡើងដោយផ្ទាល់ទៅកាន់ច្រករាយការណ៍បន្ទាន់ ឬ អង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យាដែរ។

## រូបភាព ១ នីតិវិធីក្នុងការរាយការណ៍ វាយតម្លៃ និងលុបរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ




➤ **ក្រុមហ៊ុនត្រូវបង្កើតនីតិវិធីរក្សាភស្តុតាង** ដើម្បីធានាថានៅពេលដែលរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារត្រូវបានដកចេញរួច ភស្តុតាងចាំបាច់នៅតែមានរក្សាទុកក្នុងរយៈពេលកំណត់មួយសម្រាប់ជំនួយដល់ការស៊ើបអង្កេត និងការផ្តន្ទាទោស។

ក) ការរក្សាទុកភស្តុតាង ដូចជារូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ ក្នុងរយៈពេលកំណត់មួយច្បាស់លាស់សម្រាប់ការស៊ើបអង្កេតនិងផ្តន្ទាទោស មានសារសំខាន់ខ្លាំងណាស់។ ប៉ុន្តែ ប្រសិនបើភស្តុតាងនោះត្រូវបានរក្សាទុកយូរជាងកាលកំណត់ នោះជនរងគ្រោះអាចប្រឈមជាមួយហានិភ័យកាន់តែច្រើនឡើង។ នាពេលបច្ចុប្បន្ន ច្បាប់របស់កម្ពុជា រួមទាំងក្រមព្រហ្មទណ្ឌមិនមានចែងអំពីរយៈពេលនៃការរក្សាទុកភស្តុតាងទេ ប៉ុន្តែសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាមានចែងអំពីការរក្សាទុកទិន្នន័យសម្រាប់រដ្ឋាភិបាលរហូតដល់ ១៨០ ថ្ងៃ។ ការមិនអនុវត្តតាមច្បាប់ដែលមានចែងនេះ នឹងត្រូវទទួលការពិន័យ ឬ ដាក់ពន្ធនាគារ ឬ ត្រូវទទួលទោសទាំងពីរ។

ខ. ក្រៅពីការរក្សាទុកភស្តុតាង ក្រុមហ៊ុនត្រូវកំណត់ថាតើនរណាអាចមានសិទ្ធិចូលមើលភស្តុតាងនៅក្នុងយន្តការជូនដំណឹងនិងដកចេញ។ ភស្តុតាងគួរតែបង្ហាញចំពោះតែភ្នាក់ងារអនុវត្តច្បាប់ (ក្រុមហ៊ុនអាចនឹងរាយការណ៍អំពីមាតិកានោះទៅកាន់ច្រករាយការណ៍បន្ទាន់ផងដែរ) ឬ សម្រាប់ដំណើរការនីតិវិធីផ្លូវច្បាប់ចាំបាច់ប៉ុណ្ណោះ។ ក្រុមហ៊ុនត្រូវរៀបចំបញ្ជីឈ្មោះបុគ្គលិកទាំងអស់ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារឬមាតិកាសម្ងាត់ផ្សេងទៀត។ ដោយពួកគាត់អាចធ្វើការដោយផ្ទាល់ជាមួយរូបភាពសម្ភារៈទាំងនោះ ក្រុមហ៊ុនចាំបាច់ត្រូវសម្រិតសម្រាំងត្រួតពិនិត្យថាពួកគាត់មិនធ្លាប់ប្រព្រឹត្តិបទល្មើសណាមួយប្រឆាំងនឹងកុមារពីមុនមកទេ និងត្រូវមានកម្មវិធីគាំទ្រសុខភាពផ្លូវចិត្តសម្រាប់ពួកគេផងដែរ។

គ. នីតិវិធីរក្សាទុកភស្តុតាងគួរតែចែងអំពីដំណើរការបំផ្លាញមាតិកាខុសច្បាប់ទាំងអស់នោះចោលក្រោយចប់រយៈពេលកំណត់។

**ក្រុមហ៊ុនគួរបង្កើតច្រកបញ្ជូនបន្តសម្រាប់ជនរងគ្រោះទៅក្នុងប្រព័ន្ធគាំពារកុមារផ្លូវការ។** ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល **អាចជាចំណុចទំនាក់ទំនងដំបូង** ដែលកុមាររាយការណ៍អំពីការរំលោភបំពាន។ក្រៅពីការកត់ត្រានិងការចាត់វិធានការលើការរាយការណ៍អំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ និងទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ច ក្រុមហ៊ុនចាំបាច់ត្រូវតែផ្តល់យន្តការបញ្ជូនបន្តទៅកាន់ច្រកជំនួយបន្ទាន់ (Helpline) ឬផ្តល់នូវការសម្របសម្រួលផ្សេងទៀតដែលកុមារអាចនិយាយទៅកាន់បុគ្គលណាម្នាក់អំពីស្ថានភាពរបស់ពួកគេ។ ប្រសិនបើចាំបាច់ ក្រុមហ៊ុនអាចបញ្ជូលបន្តទៅកាន់ប្រព័ន្ធគាំពារកុមារផ្លូវការ។ ការអនុវត្តសកម្មភាពទាំងនេះត្រូវមានការយល់ព្រមពីកុមារសិនដែរ។ ប្រការទាំងនេះ មានចែងក្នុងផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក៏ដូចជាសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ។

ក្រុមហ៊ុនមិនចាំបាច់ធ្វើការវាយតម្លៃហានិភ័យ ឬវិភាគពីតម្រូវការរាយការណ៍បញ្ជូនបន្តទៅកាន់ប្រព័ន្ធគាំពារកុមារផ្លូវការនោះទេ។ ការបញ្ជូនណាមួយដែលបានធ្វើឡើងទៅកាន់ច្រកជំនួយបន្ទាន់នឹងត្រូវវាយតម្លៃដោយអ្នកវិភាគ ឬអ្នកពិគ្រោះយោបល់ដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ថាតើករណីនីមួយៗត្រូវការបញ្ជូនបន្តទៅកាន់ប្រព័ន្ធគាំពារផ្លូវការឬទេ។ សូមកត់សម្គាល់ថា រាល់រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារដែលត្រូវបានរាយការណ៍តាមប្រព័ន្ធរាយការណ៍បន្ទាន់ នឹងត្រូវទទួលបានការវាយតម្លៃដើម្បីបញ្ជូនបន្ត។

## រូបភាព ២ រូបសង្ខេបស្ដីអំពីតួនាទី និងការទទួលខុសត្រូវក្នុងការរាយការណ៍ និងលុបរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ[១២]

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានតួនាទីសម្របសម្រួល មុខងារនិងតួនាទីរបស់អង្គភាពផ្សេងៗ។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ព្រមទាំងនិយ័តករទូរគមនាគមន៍ ត្រូវពិនិត្យថាក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលគោរពតាមកាតព្វកិច្ចរបស់ខ្លួន។ ភ្នាក់ងារអនុវត្តច្បាប់ជាតិ (តាមរយៈអង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា) មានតួនាទីស៊ើបអង្កេតគ្រប់ករណីទាំងអស់ដែលពាក់ព័ន្ធនឹងការរំលោភបំពាន ផ្លូវភេទកុមារតាមអនឡាញ ដែលកើតមាន ឬដែលជនរងគ្រោះស្ថិតនៅក្នុងប្រទេសកម្ពុជា។

↓

នៅក្នុងករណីខ្លះ ភ្នាក់ងារអនុវត្តច្បាប់នៅកម្ពុជាក៏អាចទទួលបានការជូនដំណឹងពីនគរបាលអន្តរជាតិ (INTERPOL) ឬភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិផ្សេងទៀត ដោយពួកគេអាចធ្វើការជូនដំណឹងឱ្យមានការដកមាតិកាចេញ ទៅកាន់ក្រុមហ៊ុននៅកម្ពុជា។ ការរាយការណ៍អាចទទួលបានតាមរយៈប្រព័ន្ធរាយការណ៍បន្ទាន់ INHOPE ឬ ICMEC នោះ ភ្នាក់ងារអនុវត្តច្បាប់នៅកម្ពុជានឹងបញ្ជាឱ្យដកចេញ។

↓

ប្រសិនបើភ្នាក់ងារអនុវត្តច្បាប់នៅកម្ពុជាជ្រាបអំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ តាមរយៈយន្តការផ្សេងទៀត ពួកគេមានតួនាទីរាយការណ៍មាតិកានោះ ដោយប្រើប្រាស់ URL ទៅកាន់ប្រព័ន្ធរាយការណ៍បន្ទាន់ INHOPE និង ICMEC ដើម្បីធានាថាមាតិកា នោះទទួលបានកំណត់សម្គាល់ Hash និងត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ។

↓

ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជាមានកាតព្វកិច្ចត្រូវឆ្លើយតបភ្លាមៗនៅពេលទទួលបានការជូនដំណឹងពីប្រព័ន្ធរាយការណ៍បន្ទាន់ ឬភ្នាក់ងារអនុវត្តច្បាប់ជាតិ ឱ្យដកមាតិកាណាមួយចេញ តែត្រូវរក្សាទុកនូវទិន្នន័យរបស់អ្នកប្រើប្រាស់មាតិកា និងរូបភាពសម្ភារៈរំលោភបំពានទាំងនោះ។

↓

បើក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលទទួលបានការជូនដំណឹងតាមយន្តការផ្សេងទៀត ដូចជាការរាយការណ៍ផ្ទាល់ពីប្រជាពលរដ្ឋ ឬកុមារ អំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ មាតិកានោះគួរត្រូវបានលុបចេញជាបណ្ដោះអាសន្ន។ ក្រុមហ៊ុនត្រូវរាយការណ៍មាតិកានោះទៅកាន់ប្រព័ន្ធរាយការណ៍បន្ទាន់ណាមួយ។ បន្ទាប់ពីវិភាគរួច ប្រសិនបើមាតិកានោះជារូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ ក្រុមហ៊ុនត្រូវលុបចោលពីការប្រើប្រាស់ឬចូលមើលរបស់សាធារណៈជន តែត្រូវរក្សាទុកមាតិកានិងទិន្នន័យអ្នកប្រើប្រាស់ជាភស្តុតាងសម្រាប់ការអនុវត្តច្បាប់។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អាចផ្ដល់ការណែនាំ និងការគាំទ្រនានា ដល់ក្រុមហ៊ុនខ្នាតតូច ក្នុងការបង្កើតនូវយន្តការទប់ស្កាត់និងឆ្លើយតបដ៏សមស្រប ដូចជាការគាំទ្រការវាយតម្លៃផលប៉ះពាល់សិទ្ធិកុមារ ការវាយតម្លៃពីឯកជនភាព និងគោលការណ៍រចនាប្រកបដោយសុវត្ថិភាពជាដើម។

[១២]UNICEF and GSMA, 2016, Notice and Takedown. Company policies and practices to remove online child sexual abuse material. Available online at https://www.gsma.com/mpoweryouth/resources/notice-and-takedown-company-policies-and-practices-to-remove-online-child-sexual-abuse-material/

# ៣. ការវាយតម្លៃលទ្ធផលនៃការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល

ដើម្បីធានាសុវត្ថិភាព ការការពារ និងសុខុមាលភាពរបស់កុមារ ជាស្នូលក្នុងផ្តល់សេវានិងផលិតផល ទាមទារនូវកិច្ចអន្តរាគមន៍ច្រើនយ៉ាង។ អន្តរាគមន៍ទាំងនោះរួមបញ្ចូលយន្តការសម្រាប់ការតាមដានដំណើរការអនុវត្ត និងលទ្ធផលស្របតាមសូចនាករដែលបានកំណត់ទុក។ ការតាមដាននេះគួរធ្វើឡើងឱ្យបានទៀងទាត់ ក្នុងចន្លោះពីមួយឆ្នាំទៅពីរឆ្នាំម្តង ដើម្បីធានាថាលទ្ធផលសម្រេចបានតាមការរំពឹងទុក ឬពុំនោះសោធ ក្រុមហ៊ុនគួរកែប្រែ និងធ្វើឱ្យប្រសើរឡើងវិញទាន់ពេលវេលា នូវគោលនយោបាយផ្ទៃក្នុងរបស់ខ្លួន ដំណើរការដែលប៉ះពាល់ដល់សិទ្ធិកុមារ ក៏ដូចជាផលិតផល និងសេវាដែលកំពុងមានលើទីផ្សារ។

ការតាមដាននេះ គួររួមបញ្ចូលទាំងការវាយតម្លៃកម្មវិធីអក្ខរកម្មឌីជីថល សុវត្ថិភាពលើប្រព័ន្ធអនឡាញ និងភាពជាពលរដ្ឋឌីជីថល ដោយផ្តោតលើការផ្លាស់ប្តូរឥរិយាបថនិងការអនុវត្ត ជាជាងតែលើការយល់ដឹង។

**ក្រុមហ៊ុនគួរបោះពុម្ពផ្សាយលទ្ធផលនៃការវាយតម្លៃទាំងនេះក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនប្រកបដោយតម្លាភាព។** ការធ្វើរបៀបនេះអាចផ្តល់នូវផលប្រយោជន៍បន្ថែមដោយធានាថាអតិថិជន និងសាធារណៈជនទូទៅបានដឹងពីជំហ៊ានសំខាន់ៗដែលក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលកំពុងអនុវត្តដើម្បីប្រាកដថាសេវានិងផលិតផលរបស់ខ្លួនមានគិតគូរអំពីសុវត្ថិភាព និងសុខុមាលភាពកុមារ។ ទម្រង់វាយតម្លៃសម្រាប់ការរាយការណ៍នៅកម្ពុជាមានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ ខ។



# ឧបសម្ព័ន្ធ ក៖
# អាយុ និងដំណាក់កាលវិវត្តរបស់កុមារ



| អាយុ/ដំណាក់កាល | ការវិវត្តសំខាន់ៗ |
|---|---|
| **០-៥**<br>**វ័យមុនរៀនអក្សរ និង ពេលរៀនអក្សរដំបូង** | មានការសិក្សាតិចតួចណាស់ស្តីពីការយល់ដឹងរបស់កុមារអំពីបរិស្ថានឌីជីថលនៅក្នុងចន្លោះអាយុនេះ ជាពិសេសចំពោះក្មេងតូចអាយុ ០-៣ឆ្នាំ។ ប៉ុន្តែភស្តុតាងខ្លះបានបង្ហាញថា កុមារជាច្រើនមានវត្តមានលើប្រព័ន្ធអនឡាញតាំងពីក្មេងតែការយល់ និងការដឹងអំពីហានិភ័យលើប្រព័ន្ធអនឡាញចំពោះកុមារនៅក្នុងចន្លោះអាយុនេះ មានកម្រិតតិចតួចណាស់។<br><br>នៅអាយុ៣-៥ ឆ្នាំ កុមារចាប់ផ្តើមអភិវឌ្ឍសមត្ថភាពក្នុងការ 'ចេះយកចិត្តគេដាក់ចិត្តខ្លួនឯង' ហើយងាយនឹងលង់ជាមួយរូបរាងខាងក្រៅណាស់។ ពួកគេកំពុងតែអភិវឌ្ឍមិត្តភាព ទោះបីជាសម្ពាធពីដៃគូមានកម្រិតទាបក៏ដោយ ក៏ការណែនាំ ឬឥទ្ធិពលពីឪពុកម្តាយ និងគ្រួសារ គឺជាគន្លឹះសំខាន់។ ពួកគេអាចរៀនធ្វើតាមការប្រាប់ច្បាស់លាស់ និងសាមញ្ញៗ ប៉ុន្តែមិនទាន់យល់ ឬអាចធ្វើតាមការប្រាប់ ឬការណែនាំពិបាកៗនោះទេ ឬធ្វើអ្វីផ្សេងៗបាន ក្រៅពីការសម្រេចចិត្តងាយៗ។ សមត្ថភាពពួកគេនៅមានកម្រិតទាំងសម្រាប់ការគ្រប់គ្រងខ្លួនឯង ឬសមត្ថភាពក្នុងការគ្រប់គ្រងពេលវេលាផ្ទាល់ខ្លួននៅលើប្រព័ន្ធអនឡាញ។ ពួកគេចូលរួមក្នុងសកម្មភាពទាំងឡាយណាដែលដឹកនាំដោយមនុស្សពេញវ័យ លេងកម្សាន្តនៅក្នុងបរិស្ថាន 'បិទជិត' ឬមើលការចាក់ផ្សាយវីដេអូជាដើម។<br><br>កុមារនៅក្នុងចន្លោះអាយុនេះ មិនសូវមានឧបករណ៍ផ្ទាល់ខ្លួនដូចជាកុមារធំៗនោះទេ ភាគច្រើនគេលេងឧបករណ៍របស់ឪពុកម្តាយដែលអាច សមស្រប ឬមិនសមស្របសម្រាប់កុមារ។ ពួកគេអាចប្រើប្រាស់ប្រដាប់ប្រដារក្មេងលេងដែលមានភ្ជាប់សេវា (ដូចជាតុក្កតាខ្លាឃ្មុំ ឬតុក្កតាចេះនិយាយ) ហើយក៏អាចធ្វើត្រាប់តាមការប្រើប្រាស់ឧបករណ៍បើកដំណើរការដោយសំឡេងរបស់ឪពុកម្តាយ ដូចជា 'home hubs' ជាដើម។<br><br>កុមារនៅក្នុងចន្លោះអាយុនេះ មិនទាន់បានចូលរៀន ឬឋិតនៅក្នុងដំណាក់កាលរៀនអក្សរដំបូង ហេតុនេះគេមិនអាចពត៌មានជាសំណេរបានទេ។<br><br>កុមារនៅចក្រភពអង់គ្លេសនៅក្នុងចន្លោះអាយុនេះមិនអាចផ្តល់ការយល់ព្រមដោយខ្លួនឯងចំពោះការដំណើរការទិន្នន័យបុគ្គលរបស់គេនៅក្នុងបរិបទសេវាតាមប្រព័ន្ធអនឡាញបានឡើយ (មាត្រា ៨(១) នៃបទប្បញ្ញត្តិស្តីពីកិច្ចការពារទិន្នន័យទូទៅ និង ៩ នៃ DPA ឆ្នាំ២០១៨)។ ដូច្នេះ ប្រសិនបើអ្នកមានបំណងស្វែងរកការយល់ព្រមស្របច្បាប់សម្រាប់ដំណើរការបុគ្គលរបស់ពួកគេ អ្នកចាំបាច់ត្រូវតែស្វែងរកការអនុញ្ញាតពីឪពុកម្តាយរបស់គេ។ |

## ៦-៩ឆ្នាំ

### វ័យចូលរៀនបឋមសិក្សា

កុមារនៅក្នុងចន្លោះអាយុនេះ ក៏មិនទាន់មានឧបករណ៍បច្ចេកវិទ្យាផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់ទេ(ដូចជា កុំព្យូទ័របន្ទះ) ប៉ុន្តែជាទូទៅគេប្រើឧបករណ៍របស់ឪពុកម្តាយ។ ពួកគេកាន់តែមានភាពឯករាជ្យក្នុងការចាប់ផ្តើមប្រើប្រាស់ឧបករណ៍ទោះមាន ឬមិនមានការកំណត់ជាក់លាក់សម្រាប់កុមារក្តី។ ប្រដាប់ប្រដាលេងដែលមានភ្ជាប់សេវាអ៊ីនធឺណិត គឺជាទីពេញនិយមសម្រាប់ពួកគេ ហើយគេអាចចូលរួមលេងដោយរីករាយដោយប្រើប្រាស់ឧបករណ៍បើកដំណើរការដោយសំឡេងដូចជា home hubs ជាដើម។

កុមារចន្លោះអាយុនេះ ជារឿយៗចូលចិត្តលេងហ្គេមអនឡាញ សកម្មភាពដែលមានភាពច្នៃប្រឌិត និងការផ្សាយវីដេអូផ្ទាល់។ កុមារអាចនឹងសាកល្បងប្រើប្រាស់បណ្តាញសង្គម ទាំងតាមរយៈហ្គេមអនឡាញ គណនីបណ្តាញសង្គមរបស់ឪពុកម្តាយ ឬតាមរយៈការបង្កើតគណនីបណ្តាញសង្គមផ្ទាល់ខ្លួន។ ពួកគេអាចភ្ជាប់ទំនាក់ទំនង និងទទួលរងឥទ្ធិពលពីអ្នកថតវីដេអូតាមប្រព័ន្ធអនឡាញ (vlogger) ជាពិសេសអ្នកដែលស្ថិតនៅក្នុងចន្លោះអាយុស្រដៀងគ្នា។

កុមារវ័យនេះអាចទទួលបានសារពីសាលារៀនអំពីសុវត្ថិភាពលើប្រព័ន្ធអនឡាញ បរិស្ថានឌីជីថល ការអភិវឌ្ឍចំណេះដឹងមូលដ្ឋានអំពីឯកជនភាព និងហានិភ័យលើប្រព័ន្ធអនឡាញមួយចំនួន។ ប៉ុន្តែ ពួកគេមិនយល់អំពីថាតើទិន្នន័យបុគ្គលរបស់ពួកគេត្រូវបានយកទៅប្រើប្រាស់ដោយរបៀបណា ឬអំពីហានិភ័យដោយប្រយោល មិនជាក់ច្បាស់ ដែលកើតចេញពីឥរិយាបថលើប្រព័ន្ធអនឡាញរបស់ពួកគេ។

កុមារក្នុងវ័យនេះងាយរងសម្ពាធពីដៃគូ ដោយពួកគេមានភាពចាំបាច់ត្រូវសម្របទៅក្នុងក្រុមដៃគូឬមិត្តភក្តិរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី សមាជិកក្នុងផ្ទះនិងគ្រួសារនៅតែជាអ្នកមានឥទ្ធិពលខ្លាំងបំផុត។ ពួកគេនៅតែមានទំនោរស្តាប់តាមសារ ឬការណែនាំពីអ្នកផ្ទះនិងសាលារៀន។ ប្រសិនបើមិនមានការពន្យល់អំពីហានិភ័យឱ្យបានច្បាស់លាស់ទេ ពួកគេអាចនឹងស្វែងយល់ដោយខ្លួនឯង ឬនឹកឃើញអំពីយុទ្ធសាស្ត្រការពារខ្លួនឯងដែលគ្មានប្រសិទ្ធភាព។

កម្រិតអក្ខរកម្មសម្រាប់កុមារពីម្នាក់ទៅម្នាក់ អាចមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ ហើយយើងមិនអាចសន្មត់បានថាពួកគេអាចទំនាក់ទំនងតាមរយៈការសរសេរឡើយ។

កុមារនៅចក្រភពអង់គ្លេសនៅក្នុងចន្លោះអាយុនេះមិនអាចផ្តល់ការយល់ព្រមដោយខ្លួនឯងចំពោះការដំណើរការទិន្នន័យបុគ្គលរបស់គេនៅក្នុងបរិបទសេវាតាមប្រព័ន្ធអនឡាញបានឡើយ (មាត្រា ៨(១) នៃបទប្បញ្ញត្តិស្តីពីកិច្ចការពារទិន្នន័យទូទៅ និង s៩ នៃ DPA ឆ្នាំ២០១៨)។ ដូច្នេះ ប្រសិនបើអ្នកមានបំណងស្វែងរកការយល់ព្រមស្របច្បាប់សម្រាប់ដំណើរការបុគ្គលរបស់ពួកគេ អ្នកចាំបាច់ត្រូវតែស្វែងរកការអនុញ្ញាតិពីឪពុកម្តាយរបស់គេ។

## ១០-១២ឆ្នាំ

### វ័យអន្តរកាល

នេះគឺជាចន្លោះអាយុដែលសកម្មភាពរបស់កុមារនៅលើប្រព័ន្ធអនឡាញមានការផ្លាស់ប្តូរជាខ្លាំង។ ក្នុងឆ្នាំអន្តរកាលចន្លោះពីថ្នាក់បឋមសិក្សាទៅវិទ្យាល័យ កុមារអាចមានឱកាសទទួលបានឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួន ភាគច្រើនជាទូរសព្ទស្មាតហ្វូន។

ពួកគេក៏មានទំនោរផ្លាស់ប្តូរទៅការប្រើប្រាស់ប្រព័ន្ធអនឡាញ ដើម្បីស្វែងរក និងបង្កើតអត្តសញ្ញាណផ្ទាល់ខ្លួននិងទំនាក់ទំនង ពង្រីកនិងរក្សាទំនាក់ទំនងជាមួយក្រុមមិត្តភក្តិ ហើយ 'សម្របខ្លួន' ទៅក្នុងសង្គម។ ចំណុចនេះអាចនាំទៅរកការកើនឡើងនៃការប្រើប្រាស់មុខងារ ឬសេវាបណ្តាញសង្គម។ កុមារនៅក្នុងចន្លោះអាយុនេះ ងាយរងសម្ពាធពីដៃគូម៉ាកសញ្ញា និង 'អ្នកមានឥទ្ធិពល' លើប្រព័ន្ធអនឡាញ និងការកើនឡើងនៃឥរិយាបថប្រថុយប្រថាន។ ការឱ្យតម្លៃខ្លួនឯង អាចនឹងធ្លាក់ចុះនៅពេលដែលកុមារប្រៀបធៀបខ្លួនទៅនឹងអ្នកដទៃ និងព្យាយាមបង្ហាញផ្នែកមួយទៀតនៃជីវិតនៅលើប្រព័ន្ធអនឡាញដើម្បីឱ្យអ្នកដទៃទទួលយកបាន និង 'ការភ័យខ្លាចបាត់បង់ការទទួលស្គាល់' អាចក្លាយជារឿងមួយដែលគួរឱ្យព្រួយបារម្ភ។

កុមារវ័យនេះនិយមចូលចិត្តលេងហ្គេមអនឡាញ មើលវីដេអូនិងតន្ត្រីផ្សាយផ្ទាល់។ កុមារអាចមានអារម្មណ៍ថា មានសម្ពាធពេលលេងហ្គេមជាមួយមិត្តភក្តិ និងមានអារម្មណ៍ថាខ្លាចគេមិនទទួលស្គាល់ឬរាប់អាន។

អាកប្បកិរិយារបស់កុមារចំពោះបម្រាម ការដាក់កំហិត និងការចូលរួមរបស់ឪពុកម្តាយ ក្នុងសកម្មភាពលើប្រព័ន្ធអនឡាញ អាចមានភាពខុសគ្នាពីម្នាក់ទៅម្នាក់។ កុមារមួយចំនួនទទួលយកការណែនាំរបស់ឪពុកម្តាយ ឯកុមារផ្សេងទៀតអាចស្វែងរកស្វ័យភាពកម្រិតខ្ពស់លើប្រព័ន្ធអនឡាញ។ ទោះជាបែបនេះក្តី ឪពុកម្តាយ និងគ្រួសារនៅតែជាប្រភពដែលមានឥទ្ធិពលជាចម្បងចំពោះកុមារនៅក្នុងចន្លោះអាយុនេះ។

កុមារក្នុងចន្លោះអាយុនេះ មានការគិតរិះគន់ទៅតាមបែបមនុស្សពេញវ័យ ប៉ុន្តែសមត្ថភាពរបស់គេចំពោះការប្រមើលមើលឃើញពីផលវិបាករយៈពេលវែងនៅមានកម្រិត ហេតុនេះគេងាយទាក់ទាញដោយប្រព័ន្ធផ្តល់រង្វាន់ និងមានទំនោរទៅរកការប្រព្រឹត្តិតាមទំនើងចិត្ត។ ហេតុនេះ ការគាំទ្រពីឪពុកម្តាយ និងការគាំទ្រផ្សេងៗនៅតែមានភាពចាំបាច់។ ប៉ុន្តែ ការគាំទ្រ ការណែនាំមិនអាចធ្វើឡើងបែបដាក់កំហិតបង្គាប់បញ្ជាដូចកុមារតូចៗនោះទេ។

កុមារនៅក្នុងចន្លោះអាយុនេះ កំពុងតែអភិវឌ្ឍការយល់ដឹងពីប្រតិបត្តិការរបស់ប្រព័ន្ធអនឡាញ ប៉ុន្តែពួកគេនៅតែមិនទាន់យល់ដឹងអំពីការប្រើប្រាស់ទិន្នន័យបុគ្គលរបស់ពួកគេ។ ថ្វីត្បិតកុមារនៅក្នុងចន្លោះអាយុនេះ មានការអភិវឌ្ឍជំនាញអក្ខរកម្មច្រើនគួរសម ពួកគេនៅតែនិយមប្រព័ន្ធផ្សព្វផ្សាយ ដូចជាមាតិកាវីដេអូទៅវិញ។

នៅប្រទេសស្កុតឡែន អាយុ ១២ ឆ្នាំ ជាអាយុសមរម្យ និងមានភាពចាស់ទុំក្នុងការមានការយល់ដឹងទូទៅអំពីការអនុវត្តសិទ្ធិការពារទិន្នន័យរបស់ខ្លួន (កំណត់នៅក្រោម ៖២០៨ នៃ DPA ២០១៨)។ បញ្ញត្តិនេះ មិនមាននៅក្នុងតំបន់ដទៃទៀតនៃចក្រភពអង់គ្លេសឡើយ តែបញ្ញត្តិនេះអាចចាត់ទុកថាជាចំណុចយោងដ៏មានប្រយោជន៍។

កុមារនៅចក្រភពអង់គ្លេសនៅក្នុងចន្លោះអាយុនេះមិនអាចផ្តល់ការយល់ព្រមដោយខ្លួនឯងចំពោះការដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់គេនៅក្នុងបរិបទនៃសេវាតាមប្រព័ន្ធអនឡាញដែលបានផ្តល់ជូនដោយផ្ទាល់ដល់កុមារ (ស្របតាមមាត្រា ៨(១) នៃបទប្បញ្ញត្តិស្តីពីកិច្ចការពារទិន្នន័យទូទៅ និង ៖៩ នៃ DPA ឆ្នាំ២០១៨)។ ដូច្នេះ ប្រសិនបើអ្នកមានបំណងស្វែងរកការយល់ព្រមស្របច្បាប់សម្រាប់ដំណើរការបុគ្គលរបស់ពួកគេ អ្នកចាំបាច់ត្រូវតែស្វែងរកការអនុញ្ញាតិពីឪពុកម្តាយរបស់គេ។

## ១៣-១៥

**វ័យជំទង់**

នៅក្នុងចន្លោះអាយុនេះ កុមារមានតម្រូវការបង្កើតអត្តសញ្ញាណដើម្បីទំនាក់ទំនងជាមួយក្រុមមិត្តភក្តិរបស់ពួកគេ។ តម្រូវការនេះធ្វើឱ្យកុមារកាន់តែចង់បានឯករាជភាព និងស្វយភាពខ្ពស់ជាងមុន។ ពួកគេអាចមិនស្តាប់បង្គាប់ ឬចាប់ផ្តើមរំកិលខ្លួនឆ្ងាយពីគុណតម្លៃដែលដាក់ចេញដោយឪពុកម្តាយ ហើយព្យាយាមគេចពីកំហិតនិងលក្ខខណ្ឌនៃការប្រើប្រាស់ផ្សេងៗរបស់ឪពុកម្តាយ និងប្រព័ន្ធអនឡាញ។ ពួកគេនិយមប្រើប្រាស់នូវកម្មវិធីទាំងឡាយដែលឪពុកម្តាយមិនចេះប្រើ ឬមិនធ្លាប់ប្រើប្រាស់ ដោយសារតែកម្មវិធីទាំងនោះប្រើប្រាស់ភាសាដែលឪពុកម្តាយមិនយល់។ ទោះបីជាយ៉ាងណា ក្រុមគ្រួសារនៅតែមានឥទ្ធិពលសំខាន់មួយទៅលើកុមារនៅក្នុងចន្លោះអាយុនេះ។

ការប្រើប្រាស់មុខងារ និងកម្មវិធីបណ្តាញសង្គមផ្សេងៗមានការរីកសាយភាយយ៉ាងទូលំទូលាយ ហើយការលេងហ្គេម វីដេអូនិងតន្ត្រីផ្សាយផ្ទាល់នៅតែពេញនិយម។ កុមារអាចព្យាយាមធ្វើត្រាប់តាម 'អ្នកមានឥទ្ធិពល' ឬអ្នកថតវីដេអូសកម្មភាពនៅលើប្រព័ន្ធអនឡាញ ក្នុងដំណាក់កាលនៃការវិវត្តនេះ។

កុមារវ័យនេះ អាចនៅតែស្វែងរកជំនួយពីឪពុកម្តាយ ប្រសិនបើពួកគេជួបប្រទះបញ្ហានៅលើប្រព័ន្ធអនឡាញ ប៉ុន្តែកុមារមួយចំនួនផ្សេងទៀតអាចមានភាពស្ទាក់ស្ទើរក្នុងការស្វែងរកជំនួយពីឪពុកម្តាយ ព្រោះពួកគេបារម្ភអំពីប្រតិកម្មតបរបស់ឪពុកម្តាយចំពោះសកម្មភាពរបស់ខ្លួននៅលើប្រព័ន្ធអនឡាញ។

តាមការវិវត្ត កុមារមានកកើតឧត្តមគតិ ឬគំនិតផ្ទុយផ្ទាល់ខ្លួន ហើយងាយរងទៅនឹងការប្រៀបធៀបជាអវិជ្ជមានរវាងខ្លួនឯងនិងអ្នកដទៃ។ ពួកគេអាចមិនទាន់ទុកចិត្តសមត្ថភាពរបស់ខ្លួន ក្នុងការដោះស្រាយឬសម្រេចខ្លួនចំពោះហានិភ័យ បញ្ហាប្រឈមដែលកើតឡើងពីឥរិយាបទ និងទំនាក់ទំនងនៅលើប្រព័ន្ធអនឡាញ ហេតុនេះគេអាចនៅតែស្វែងរកការគាំទ្រពីឪពុកម្តាយ។

ជំនាញអក្ខរកម្មរបស់កុមារវ័យនេះមានការអភិវឌ្ឍច្រើនជាមុន ប៉ុន្តែពួកគេអាចនៅតែទទួលបានអត្ថប្រយោជន៍ពីការជ្រើសរើសយកប្រព័ន្ធផ្សព្វផ្សាយ។

កុមារអាយុ១៣ឆ្នាំ នៅចក្រភពអង់គ្លេសអាចផ្តល់ការយល់ព្រមដោយខ្លួនឯងចំពោះដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់គេនៅក្នុងបរិបទនៃសេវាតាមប្រព័ន្ធអនឡាញដែលបានផ្តល់ជូនដោយផ្ទាល់ដល់កុមារ (តាមបញ្ញត្តិនៃមាត្រា ៨(១) នៃបទប្បញ្ញត្តិស្តីពីកិច្ចការពារទិន្នន័យទូទៅ (GDPR) និង ៩ នៃ DPA ឆ្នាំ២០១៨)។

## ១៦-១៧

### អាយុពេញវ័យ

ក្នុងវ័យនេះ កុមារភាគច្រើនមានជំនាញលើប្រព័ន្ធអនឡាញ យុទ្ធសាស្ត្រសម្របខ្លួន និងភាពធន់បានយ៉ាងពេញលេញ។ ប៉ុន្តែ ពួកគេនៅត្រូវការអភិវឌ្ឍផ្នែកបញ្ញា ស្មារតី ភាពអត់ធន់ បទពិសោធន៍ និងការវាយតម្លៃទៅលើផលវិបាករយៈពេលវែងអំពីសកម្មភាពលើប្រព័ន្ធអនឡាញ ។

ចំណេះដឹង និងសមត្ថភាពបច្ចេកទេសអាចនឹងមានការអភិវឌ្ឍល្អប្រសើរជាងចំណេះដឹងផ្នែកអារម្មណ៍ ឬសមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងទំនាក់ទំនងដ៏ស្មុគស្មាញរបស់ខ្លួន។ សមត្ថភាពក្នុងការគិតគូររយៈពេលវែងកំពុងតែវិវត្តនៅឡើយ ហេតុនេះពួកគេអាចនៅមានទំនោរទៅរកការប្រព្រឹត្តិយ៉ាងប្រថុយប្រថាន ឬឥរិយាបទតាមទំនើងចិត្ត ព្រមទាំងងាយទទួលឥទ្ធិពលពីប្រព័ន្ធផ្តល់រង្វាន់។

គេអាចត្រូវការ ឬមិនត្រូវការការគាំទ្រពីឪពុកម្តាយ ដោយមូលហេតុសមរម្យណាមួយ។ ការផ្សព្វផ្សាយពីប្រភពគាំទ្រផ្សេងទៀតដល់កុមារវ័យនេះបន្ថែមពីលើការគាំទ្រពីឪពុកម្តាយ មានសារៈសំខាន់ណាស់។

តាមបញ្ញត្តិនៃមាត្រា ៨(១) នៃ បទប្បញ្ញត្តិស្តីពីកិច្ចការពារទិន្នន័យទូទៅ(GDPR) និង ៩ នៃ DPA ឆ្នាំ២០១៨ កុមារនៅចក្រភពអង់គ្លេសនៅក្នុងចន្លោះអាយុនេះអាចផ្តល់ការយល់ព្រមដោយខ្លួនឯងចំពោះការដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់គេនៅក្នុងបរិបទនៃសេវាតាមប្រព័ន្ធអនឡាញដែលបានផ្តល់ជូនដោយផ្ទាល់ដល់កុមារ ។

*ប្រភព៖ ការិយាល័យគណៈកម្មការព័ត៌មាន ឆ្នាំ២០២១ការរចនាសមស្របតាមអាយុ៖ ក្រមប្រតិបត្តិសម្រាប់សេវាលើប្រព័ន្ធអនឡាញ។ ICO: ទីក្រុងឡុង*



# ឧបសម្ព័ន្ធ ខ៖ បញ្ជីត្រួតពិនិត្យអនុលោមភាពនៃការឆ្លើយតប របស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល

របៀបប្រើប្រាស់បញ្ជីនេះ៖

១ បញ្ជីខាងក្រោមអាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរាយការណ៍ប្រកបដោយតម្លាភាពជាប្រចាំឆ្នាំ ឬសម្រាប់រយៈពេលណាមួយដើម្បីឆ្លុះបញ្ចាំងពីសកម្មភាពដែលក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលទាំងអស់ បានអនុវត្ត ជាកាតព្វកិច្ចនិងជាការតាំងចិត្តរបស់ខ្លួនក្នុងការការពារសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ។

២ ចំនុចដែលសសេរជា**អក្សរដិតធំ** គឺជាស្តង់ដារអប្បបរមា ដែលក្រុមហ៊ុនទាំងអស់ត្រូវវាយតម្លៃខ្លួនឯងនិងអាចរាយការណ៍ពីជំហ៊ានដែលត្រូវអនុវត្តដើម្បីសម្រេចនូវលទ្ធផលទាំងនោះ។ ចំណែកឯចំនុចដែលសសេរជា *អក្សរទ្រេត* គឺជាជំហានដែលក្រុមហ៊ុនទាំងអស់គួរអនុវត្តដើម្បីសម្រេចលទ្ធផលជាបន្ត។ ក្នុងចំណុចទាំងនេះ ក្រុមហ៊ុនខ្នាតតូច រួមទាំងធុរកិច្ចថ្មីឌីជីថលអាចត្រូវការពេលវេលាដើម្បីសម្រេចបានលទ្ធផលរំពឹងទុក។

៣ ប្រសិនបើចំនុចខ្លះមិនជាប់ពាក់ព័ន្ធនឹងសេវាឬផលិតផលរបស់ក្រុមហ៊ុនទេ ក្រុមហ៊ុនអាចកត់ចំណាំនៅក្នុងចំនុចមិនពាក់ព័ន្ធ។ ក្រុមហ៊ុនគួរពិនិត្យឆ្លុះបញ្ចាំងបន្ថែមទៀតថាហេតុអ្វីបានជាចំនុចនេះមិនជាប់ពាក់ព័ន្ធនឹងសេវាឬផលិតផលក្រុមហ៊ុនខ្លួន។

៤ ជំហ៊ាននីមួយៗសុទ្ធតែឆ្លុះបញ្ចាំងនូវគោលការណ៍ និងការតាំងចិត្តគោរពសិទ្ធិកុមារ ការទទួលស្គាល់ពីការវិវត្ត និងការផ្លាស់ប្តូរសមត្ថភាពរបស់កុមារ នៅក្នុងដំណើរការអាជីវកម្មទាំងមូល។ បញ្ជីនេះគួរតែជាឯកសាររស់ដូចទៅនឹងគោលការណ៍ណែនាំដែរ ហើយអាចកែប្រែបានស្របតាមការវិវត្តរបស់បច្ចេកវិទ្យា ហានិភ័យ និងបទពិសោធន៍របស់កុមារដែលទទួលរងគ្រោះពីហានិភ័យទាំងនោះ។

៥ ក្រុមហ៊ុននៅតែអាចរាយការណ៍ពីវិធានការណ៍បន្ថែម ពីលទ្ធផលនិងគោលការណ៍ផ្សេងទៀតក្រៅពីបញ្ជីខាងក្រោម ដែលគេបានដាក់ចេញដើម្បីការពារសិទ្ធិ សុវត្ថិភាពនិងសុខុមាលភាពកុមារអនឡាញ។

| ផ្នែក | | វិធានការ | អនុលោមភាព | | | |
|---|---|---|---|---|---|---|
| | | | ដោយផ្នែក | បាទ/ចាស | ទេ | មិនពាក់ព័ន្ធ N/A |
| ការវាយតម្លៃផលប៉ះពាល់សិទ្ធិកុមារ | ១ | **ក្រុមហ៊ុនបានអនុវត្តការវាយតម្លៃផ្ទៃក្នុងពីផលប៉ះពាល់សិទ្ធិកុមារ** | ☐ | ☐ | ☐ | ☐ |
| | *២* | *ក្រុមហ៊ុនបានផ្សព្វផ្សាយជាសាធារណៈអំពីលទ្ធផលនៃការវាយតម្លៃផលប៉ះពាល់សិទ្ធិកុមារ* | ☐ | ☐ | ☐ | ☐ |
| | ៣ | **ក្រុមហ៊ុនបានបង្កើតឬចាត់តាំងបុគ្គលិក/ការិយាល័យផ្ទៃក្នុងទទួលបន្ទុកសិទ្ធិកុមារ** | ☐ | ☐ | ☐ | ☐ |
| | ៤ | **ក្រុមហ៊ុនបានបង្ហាញអំពីសកម្មភាពអនុវត្តឬដំណោះស្រាយឆ្លើយតបទៅនឹងលទ្ធផលនៃការវាយតម្លៃផលប៉ះពាល់សិទ្ធិកុមារ *(ដោយផ្តល់ឧទាហរណ៍រឹងមាំ)*** | ☐ | ☐ | ☐ | ☐ |
| | ៥ | **ក្រុមហ៊ុនបានបង្ហាញអំពីការវាយតម្លៃអំពីផលប៉ះពាល់សុវត្ថិភាពដែលកើតចេញនៃផលិតផលឬសេវារបស់ខ្លួន *(ដោយផ្តល់ឧទាហរណ៍រឹងមាំ)*** | ☐ | ☐ | ☐ | ☐ |
| | ៦ | **ក្រុមហ៊ុនបានបង្កើតយន្តការរាយការណ៍សម្រាប់បណ្តឹងតវ៉ាពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិអ្នកប្រើប្រាស់(រួមទាំងសិទ្ធិកុមារ)** | ☐ | ☐ | ☐ | ☐ |
| | ៧ | **ក្រុមហ៊ុនមាននិងបានធ្វើបច្ចុប្បន្នភាពគោលនយោបាយការពារសុវត្ថិភាពកុមារ** | ☐ | ☐ | ☐ | ☐ |
| | ៨ | **និយោជិតដឹងអំពីគោលនយោបាយ និងកន្លែងដែលត្រូវរាយការណ៍អំពីករណីប៉ះពាល់សុវត្ថិភាពកុមារ** | ☐ | ☐ | ☐ | ☐ |
| | *៩* | *ក្រុមហ៊ុនបានធ្វើ "សវនកម្ម" ទៅលើយន្តការឯកជនភាពរបស់អ្នកប្រើប្រាស់ និងប្រព័ន្ធការពារទិន្នន័យ* | ☐ | ☐ | ☐ | ☐ |
| | *១០* | *ក្រុមហ៊ុនបានផ្សព្វផ្សាយជាសាធារណៈពីលទ្ធផលនៃកិច្ចសវនកម្មយន្តការឯកជនភាព និងការការពារទិន្នន័យ* | ☐ | ☐ | ☐ | ☐ |
| ការរចនាប្រកបដោយសុវត្ថិភាព និងឯកជនភាព | ១១ | **ក្រុមហ៊ុនបានអនុវត្តវិធានការធានាឯកជនភាព និងការការពារទិន្នន័យ រួមទាំងការកាត់បន្ថយការប្រមូលទិន្នន័យ ការដាក់កម្រិតគោលបំណងប្រើប្រាស់ ការដាក់កំហិតរយៈពេលរក្សាទុកទិន្នន័យ និងការរក្សាសុវត្ថិភាពទិន្នន័យ** | ☐ | ☐ | ☐ | ☐ |
| | ១២ | **ក្រុមហ៊ុនបានកាត់បន្ថយការប្រមូលទិន្នន័យនៅគ្រប់សេវារបស់ខ្លួន** | ☐ | ☐ | ☐ | ☐ |
| | ១៣ | **ក្រុមហ៊ុនបានដាក់កម្រិតគោលបំណងប្រើប្រាស់ទិន្នន័យនៅគ្រប់សេវារបស់ខ្លួន** | ☐ | ☐ | ☐ | ☐ |
| | ១៤ | **ក្រុមហ៊ុនបានកំហិតរយៈពេលរក្សាទុកទិន្នន័យនៅគ្រប់សេវារបស់ខ្លួន** | ☐ | ☐ | ☐ | ☐ |
| | ១៥ | **ក្រុមហ៊ុនបានធានាសុវត្ថិភាពសន្តិសុខទិន្នន័យនៅគ្រប់សេវារបស់ខ្លួន** | ☐ | ☐ | ☐ | ☐ |
| | *១៦* | *ក្រុមហ៊ុនបានអនុវត្តជំហានជាក់ស្តែងដើម្បីវាយតម្លៃយ៉ាងសុក្រឹត និងធានាអំពីអាយុរបស់អ្នកប្រើប្រាស់តាមការកំណត់របស់ខ្លួន* | ☐ | ☐ | ☐ | ☐ |
| | ១៧ | **ក្រុមហ៊ុនបានជូនដំណឹងច្បាស់លាស់ដល់អ្នកប្រើប្រាស់អំពីការប្រមូលការប្រើប្រាស់ទិន្នន័យ និងគោលបំណងនៃការប្រមូលទិន្នន័យ** | ☐ | ☐ | ☐ | ☐ |
| | ១៨ | **គោលនយោបាយ និងព័ត៌មានអំពីទិន្នន័យរបស់ក្រុមហ៊ុនអាចរកមើលបានយ៉ាងងាយស្រួល និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ** | ☐ | ☐ | ☐ | ☐ |

| | | | | | | |
|---|---|---|---|---|---|---|
| រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ | ១៩ | **ក្រុមហ៊ុនមានឬបានធ្វើបច្ចុប្បន្នភាព ក្រមប្រតិបត្តិរបស់ខ្លួន ដែលបញ្ជាក់អំពីវិធីសាស្ត្រមិនអត់ឱនជាដាច់ខាតចំពោះ រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាដែលប្រើប្រាស់បច្ចេកវិទ្យា និងការពិន័យពាក់ព័ន្ធ** | ☐ | ☐ | ☐ | ☐ |
| | ២០ | **ក្រុមហ៊ុនផ្សព្វផ្សាយជាសាធារណៈនូវលក្ខខណ្ឌនៃការប្រើប្រាស់សេវា និង/ឬ គោលនយោបាយអំពីការប្រើប្រាស់ដែលអាចទទួលយកបាន ដែលហាមឃាត់ជាដាច់ខាតនូវ រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញគ្រប់ទម្រង់ទាំងអស់** | ☐ | ☐ | ☐ | ☐ |
| | ២១ | *លក្ខខណ្ឌនៃការប្រើប្រាស់សេវា និងគោលនយោបាយអំពីការប្រើប្រាស់បានសរសេរជាភាសាដែលអាចយល់បាន និងងាយស្រួលដល់កុមារ ជនមានពិការភាព និងឪពុកម្តាយ ឬអ្នកថែទាំដែលមានចំណេះដឹងឌីជីថលតិចតួច* | ☐ | ☐ | ☐ | ☐ |
| | ២២ | **ក្រុមហ៊ុនមានប្រព័ន្ធរាយការណ៍អំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ(អាចជាតំណភ្ជាប់ទៅកាន់ច្រករាយការណ៍បន្ទាន់ INHOPE IWF ឬ NCMEC)** | ☐ | ☐ | ☐ | ☐ |
| | ២៣ | **គេហទំព័រ/តំណភ្ជាប់ប្រព័ន្ធរាយការណ៍ (ខាងលើ) មានភាពងាយស្រួលក្នុងការប្រើប្រាស់ និងអាចប្រើប្រាស់បានដោយកុមារ និងអ្នកដែលមានជំនាញចំណេះដឹងឌីជីថលតិចតួច** | ☐ | ☐ | ☐ | ☐ |
| | ២៤ | *ក្រុមហ៊ុនបានសម្រិតសម្រាំងត្រួតពិនិត្យបុគ្គលិកដែលអាចពាក់ព័ន្ធនឹងការងារជូនដំណឹង និងចេញដីកាបង្គ្រាប ឬចូលរួមនៅក្នុងការកំណត់អត្តសញ្ញាណរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ ដោយពិនិត្យមើលលិខិតថ្កោលទោសរបស់ពួកគេ។* | ☐ | ☐ | ☐ | ☐ |
| | ២៥ | **ក្រុមហ៊ុនមានទំនាក់ទំនង ជាមួយច្រករាយការណ៍បន្ទាន់ (CSAM Hotline)** | ☐ | ☐ | ☐ | ☐ |
| | ២៦ | **ក្រុមហ៊ុនរក្សាទុកចំនួននៃការរាយការណ៍ សកម្មភាព ព្រមទាំងលទ្ធផលឆ្លើយតបទៅនឹងការរាយការណ៍ទាំងអស់** | ☐ | ☐ | ☐ | ☐ |
| | ២៧ | *ក្រុមហ៊ុនបានប្រើកម្មវិធីសុសវែរដើម្បីស្វែងរករូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារដោយស្វ័យប្រវត្តិ(ករណីនេះសម្រាប់តែប្រតិបត្តិករទូរស័ព្ទចល័ត ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត និងអ្នកផ្តល់សេវាមាតិកាផ្សេងទៀត)* | ☐ | ☐ | ☐ | ☐ |
| | ២៨ | *ក្រុមហ៊ុនបានបិទURLs ដែលកំណត់អត្តសញ្ញាណដោយប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ ICCAM, NICMEC, IWF ។* | ☐ | ☐ | ☐ | ☐ |
| | ២៩ | **ក្រុមហ៊ុនបានចងក្រងឯកសារនីតិវិធី/ពិធីសារ ជូនដំណឹង និងដកចេញ និងគោលនយោបាយកំណត់រយៈពេលរក្សាទុកភស្តុតាង** | ☐ | ☐ | ☐ | ☐ |
| | ៣០ | **ក្រុមហ៊ុនមានបញ្ជាក់អំពីដំណើរការបំផ្លាញទិន្នន័យ ការប្រើប្រាស់ព័ត៌មាន និងមាតិការូបភាពសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ បន្ទាប់ពីផុតពេលកំណត់រក្សាទុក** | ☐ | ☐ | ☐ | ☐ |
| | ៣១ | **ក្រុមហ៊ុនអាចកំណត់ដំណើរការរាយការណ៍រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ (ការរាយការណ៍ជូនដល់ អង្គភាពប្រឆាំងបទល្មើសបច្ចេកវិទ្យា)** | ☐ | ☐ | ☐ | ☐ |
| | ៣២ | *ក្រុមហ៊ុនអាចផ្តល់ដំណើរការ និងយន្តការបញ្ជូនត្រឹមត្រូវទៅកាន់ប្រព័ន្ធគាំពារកុមារកម្ពុជា (ច្រកជំនួយបន្ទាន់ ឬ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា)* | ☐ | ☐ | ☐ | ☐ |

| | | | | | | |
|---|---|---|---|---|---|---|
| បរិស្ថានសុវត្ថិភាពលើប្រព័ន្ធអនឡាញ | ៣៣ | **ក្រុមហ៊ុនបានគិតគូរពីការរចនាប្រកបដោយសុវត្ថិភាព ឯកជនភាព និងសមស្របតាមអាយុ សម្រាប់សេវាទាំងឡាយដែលអាចចូលប្រើប្រាស់ដោយកុមារ** | ☐ | ☐ | ☐ | ☐ |
| | ៣៤ | *ក្រុមហ៊ុនបានដាក់ដំណើរការទម្រង់មួយចំនួននៃប្រព័ន្ធសម្របសម្រួលសមស្របតាមអាយុដែលមិនរំលោភបំពានលើសិទ្ធិកុមារ ក្នុងការទទួលបានឯកជនភាព ឬសិទ្ធិទទួលបានព័ត៌មាន ឬសិទ្ធិក្នុងការចូលរួមចំពោះសេវានិងផលិតផលសម្រាប់កុមារ* | ☐ | ☐ | ☐ | ☐ |
| | ៣៥ | **ក្រុមហ៊ុនបានបញ្ជាក់ច្បាស់លាស់អំពីដែនកំណត់នៃមុខងារគ្រប់គ្រងដោយឪពុកម្តាយទាំងនេះ និងរបៀបត្រឹមត្រូវក្នុងការប្រើប្រាស់មុខងារទាំងនេះ** | ☐ | ☐ | ☐ | ☐ |
| | ៣៦ | **ក្រុមហ៊ុនបានផ្តល់ការកំណត់ឯកជនភាពជាជម្រើសដើម(Privacy by default) និងមានជម្រើសបិទមុខងារឬកម្មវិធីផ្សេងៗទៀតយ៉ាងងាយស្រួល(Op-out options)** | ☐ | ☐ | ☐ | ☐ |
| ការអប់រំ និងការលើកកម្ពស់ការយល់ដឹង | ៣៧ | *ក្រុមហ៊ុនបានចូលរួមអនុវត្តកម្មវិធីលើកកម្ពស់អក្ខរកម្មឌីជីថល* | ☐ | ☐ | ☐ | ☐ |
| | ៣៨ | *ក្រុមហ៊ុនបានចូលរួមអនុវត្តកម្មវិធីលើកកម្ពស់អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ* | ☐ | ☐ | ☐ | ☐ |
| | ៣៩ | *ក្រុមហ៊ុនបានគាំទ្រ ឬផ្តល់ជូនដោយផ្ទាល់នូវការអប់រំអំពីការបង្ការ ឬទប់ស្កាត់  និងការផ្លាស់ប្តូរឥរិយាបថសង្គម* | ☐ | ☐ | ☐ | ☐ |
| | ៤០ | *ក្រុមហ៊ុនបានចាប់ដៃគូជាមួយក្រុមហ៊ុនមិនមែនបច្ចេកវិទ្យា អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលដើម្បីអនុវត្តកម្មវិធីណាមួយក្នុងចំណោមកម្មវិធីខាងលើ* | ☐ | ☐ | ☐ | ☐ |
| | ៤១ | *ក្រុមហ៊ុនបានគាំទ្រការស្រាវជ្រាវ និងការបង្កើតភស្តុតាងពាក់ព័ន្ធនឹងអំពើហិង្សាដោយប្រើប្រាស់បច្ចេកវិទ្យា និងសុវត្ថិភាពលើប្រព័ន្ធអនឡាញ* | ☐ | ☐ | ☐ | ☐ |
| | ៤២ | *ក្រុមហ៊ុនបានធ្វើការស្រាវជ្រាវនិងអភិវឌ្ឍ ដើម្បីបង្កើតដំណោះស្រាយបច្ចេកវិទ្យាថ្មីៗ ប្រឆាំងនឹងការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ* | ☐ | ☐ | ☐ | ☐ |



# ឧបសម្ព័ន្ធ គ៖ សទ្ទានុក្រម

| វាក្យសព្ទ | និយមន័យ |
|---|---|
| **ការរចនាស្របតាមអាយុ**<br>**Age-Appropriate Design** | ការគិតគូរពិចារណាអំពីអាយុរបស់អ្នកប្រើសេវាឬផលិតផល ការវិវត្តសមត្ថភាព និងដំណាក់កាលលូតលាស់របស់កុមារ ព្រមទាំងហានិភ័យពាក់ព័ន្ធទៅក្នុងការរចនានិងការអភិវឌ្ឍផលិតផល ឬសេវាថ្មីៗណាមួយ។ ការរចនានេះធានាថា ផលប៉ះពាល់នៃសេវា ឬផលិតផល លើកុមារដែលមានអាយុផ្សេងៗគ្នា ត្រូវបានគិតគូរចាប់ពីដើមដំបូងនៃការអភិវឌ្ឍផលិតផល/សេវា ហើយឆ្លុះបញ្ចាំងអំពីការលូតលាស់ និងការអភិវឌ្ឍសមត្ថភាពរបស់កុមារនឹងមិនបង្កឱ្យមានហានិភ័យដល់សុខុមាលភាព និងសិទ្ធិរបស់កុមារ។<br><br>ការរចនាស្របតាមអាយុក៏មានន័យថា ផ្ដល់ឱកាសសម្រាប់ការរីកចម្រើន និងការអភិវឌ្ឍស្របទៅតាមលក្ខខណ្ឌនិងតម្រូវលូតលាស់របស់កុមារ។ |
| **ការផ្ទៀងផ្ទាត់អាយុ**<br>**Age-verification**<br><br>*កំណត់ពន្យល់នៃសេចក្ដីព្រាងច្បាប់ស្ដីពីសុវត្ថិភាពលើប្រព័ន្ធអនឡាញរបស់ចក្រភពអង់គ្លេស (សេចក្ដីព្រាងចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២), ២៨៥- EN, វាក្យខណ្ឌ ៣៨១។* | វិធានការបច្ចេកទេសដើម្បីត្រួតពិនិត្យអាយុអ្នកប្រើប្រាស់មុនផ្តល់ការអនុញ្ញាតឱ្យចូលមើលមាតិកាផ្សេងៗដែលអាចមិនសមស្របតាមអាយុ។<br><br>*(គួរប្រើប្រាស់ឧបសម្ព័ន្ធលេខ២ ដើម្បីពិនិត្យលើអាយុនិងការវិវត្ត)* |
| **បញ្ញាសិប្បនិម្មិត**<br>**Artificial Intelligence**<br><br>*គោលការណ៍ណែនាំសម្រាប់ឧស្សាហកម្មស្ដីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ ឆ្នាំ២០២០ របស់សហភាពទូរគមនាគមន៍អន្តរជាតិ* | បញ្ញាសិប្បនិម្មិត (AI) សំដៅដល់ប្រព័ន្ធដែលជាប្រតិដ្ឋកម្មវិទ្យាសាស្ត្រ (បញ្ញាសិប្បនិម្មិត “ខ្លាំង” ដែលមានញាណដឹងដោយខ្លួនឯង) និងប្រព័ន្ធប្រតិបត្តិការមានសមត្ថភាពអនុវត្តកិច្ចការ ស្មុគស្មាញ ( បញ្ញាសិប្បនិម្មិត “ខ្សោយ” ឬ “មធ្យម” ដូចជា បច្ចេកវិទ្យាសម្គាល់មុខ ឬសំឡេង និង ប្រព័ន្ធបើកបរយានយន្តស្វ័យប្រវត្តិកម្មជាដើម)។ |

| | |
|---|---|
| **កុមារ**<br>**Child**<br>*សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ឆ្នាំ២០២២ និងអនុសញ្ញាស្តីអំពីសិទ្ធិកុមារ* | បុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ |
| **កិច្ចការពារសុវត្ថិភាពកុមារ**<br>**Child Safeguarding** | កិច្ចការពារសុវត្ថិភាពកុមារ សំដៅទៅលើបណ្តុំនៃគោលនយោបាយ ដំណើរការ និងការអនុវត្តនានា ដើម្បីបង្ការទប់ស្កាត់គ្រោះថ្នាក់ ឬបញ្ហានានាលើកុមារ។ ការការពារសុវត្ថិភាពផ្តោតសំខាន់ជាពិសេសទៅលើវិធានការទប់ស្កាត់ ដើម្បីធានាថាកុមារគឺត្រូវបានការពារពីសកម្មភាពទាំងឡាយទាំងចេតនា ឬអចេតនា នាំឱ្យមានហានិភ័យ ឬគ្រោះថ្នាក់ជាក់ស្តែង។ |
| **ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ**<br>**Child Sexual Exploitation and Abuse**<br>*មាត្រា១៨ អនុសញ្ញាក្រុមប្រឹក្សាអឺរ៉ុបស្តីពីការការពារកុមារ និងប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ (អនុសញ្ញា Lanzarote) ECPAT*<br>*គោលការណ៍ណែនាំសម្រាប់ការការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទនិងការរំលោភបំពានផ្លូវភេទ។ អនុម័តដោយក្រុមការងារអន្តរភ្នាក់ងារក្នុងប្រទេសលុចសំបួរ ថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១៦*<br>*គោលការណ៍ណែនាំទាក់ទងនឹងការអនុវត្តពិធីសារជម្រើសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារអំពីការជួញដូរកុមារ ពេស្យា ចារកម្មកុមារ និងរូបភាពអាស អាភាសកុមារ CRC/C/១៥៦ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១៩ របស់គណៈកម្មាធិការសិទ្ធិកុមារ* | ការរំលោភបំពានផ្លូវភេទរួមបញ្ចូល៖<br>(ក)ការប្រព្រឹត្តិសកម្មភាពផ្លូវភេទជាមួយកុមារ ដែលមិនទាន់គ្រប់អាយុសម្រាប់ការរួមភេទ(លក្ខណៈមិនរាប់បញ្ចូលទំនាក់ទំនងផ្លូវភេទរបស់កុមារដូចគ្នាដែលមានការស្ម័គ្រចិត្តនោះទេ)។<br>(ខ)ការប្រព្រឹត្តិសកម្មភាពផ្លូវភេទជាមួយកុមារដោយបង្ខំ ការប្រើកម្លាំង ឬដោយការគម្រាមកំហែង ឬជាការរំលោភបំពានលើកុមារដោយសារទទួលបានការទុកចិត្ត មានអំណាចគ្រប់សង្កត់ ឬមានឥទ្ធិពលលើកុមារ ដូចជាក្នុងករណីសកម្មភាពកើតឡើងដោយសមាជិកគ្រួសារ ឬការរំលោភបំពានទៅលើកុមារដែលទន់ខ្សោយ មានពិការភាពទាំងផ្លូវកាយនិងផ្លូវចិត្ត ឬក្នុងស្ថានភាពដែលកុមារត្រូវការពឹងពាក់។<br>ការរំលោភបំពានផ្លូវភេទកុមារបានប្រែក្លាយជាការកេងប្រវ័ញ្ចផ្លូវភេទនៅពេលដែលអ្នកប្រព្រឹត្តិទទួលបានប្រាក់កម្រៃតាមរយៈសកម្មភាពផ្លូវភេទជាមួយកុមារ។ ទាំងនេះរួមបញ្ចូលសកម្មភាពគ្រោះថ្នាក់ជាច្រើនទៀតដូចជា ការលួងលោម និងការកេងប្រវ័ញ្ចកុមារនៅក្នុងផ្ទះបនជាដើម និងក្នុងស្ថានភាពនៃការផ្តល់ឬការសន្យាផ្តល់ជារង្វាន់ ប្រាក់កម្រៃការទូទាត់ផ្សេងៗជាការតបស្នងទៅនឹងការសកម្មភាពផ្លូវភេទជាមួយកុមារណាម្នាក់។<br>ទោះបីជា ពាក្យទាំងពីរពេលខ្លះត្រូវបានប្រើប្រាស់ក្នុងន័យដូចគ្នាក៏ដោយ ប៉ុន្តែភាពខុសគ្នារវាងពាក្យទាំងពីរនេះគឺ ការកេងប្រវ័ញ្ចផ្លូវភេទកុមារមានបង្កប់លក្ខណៈបែបជួញដូរ។ |

| | |
|---|---|
| **រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ**<br>**Child Sexual Exploitation and Abuse**<br><br>*គោលការណ៍ណែនាំទាក់ទងនឹងការអនុវត្តពិធីសារជម្រើសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារអំពីការជួញដូរកុមារ ពេស្យា ចារកម្មកុមារ និងរូបភាពអាសអាភាសកុមារ CRC/C/១៥៦ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៩ កថាខណ្ឌទី ៦០ របស់គណៈកម្មាធិការសិទ្ធិកុមារ*<br><br>*សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ព្រះរាជាណាចក្រកម្ពុជា* | រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ មានចែងក្នុងមាត្រា២ នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ផ្នែកការជួញដូរកុមារពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ។ រូបភាពសម្ភារៈរំលោភបំពានកុមារត្រូវបានផ្តល់និយមន័យថាជាការបង្ហាញរូបភាពនៃសកម្មភាពផ្លូវភេទកុមារទោះជាសកម្មភាពពិតជាក់ស្តែង ឬការសម្តែង ឬការបង្ហាញពីកេរ្តិ៍ភេទកុមារក្នុងគោលបំណងផ្លូវភេទ។<br><br>គណៈកម្មាការសិទ្ធិកុមារបានផ្តល់អនុសាសន៍ឱ្យរដ្ឋជាសមាជិក ចៀសវាងការប្រើប្រាស់ពាក្យ "រូបភាពអាសអាភាសកុមារ" ជំនួសវិញដោយពាក្យ "ការប្រើប្រាស់កុមារក្នុងការសម្តែងនិងការបង្កើតរូបភាពអាសអាភាស", "រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ" និង "រូបភាពសម្ភារៈកេងប្រវ័ញ្ចផ្លូវភេទកុមារ"។ |
| **ការបង្ហាញរូបភាពតាមប្រព័ន្ធអនឡាញ**<br>**Cyberflashing** | ការផ្ញើរូបភាពឬវីដេអូអំពីប្រដាប់ភេទតាមរយៈបច្ចេកវិទ្យាឌីជីថល ទៅកាន់នរណាម្នាក់ដោយគ្មានការព្រមព្រៀង។ |
| **ការរុកគួនឆាឆៅនៅតាមប្រព័ន្ធអនឡាញ**<br>**Cyberbullying** | ការរុកគួនឆាឆៅនៅតាមប្រព័ន្ធអនឡាញជាសកម្មភាពកោងកាចដែលធ្វើឡើងដោយបុគ្គលណាម្នាក់ ឬក្រុមមនុស្សណាមួយចំពោះជនរងគ្រោះដែលមិនអាចការពារខ្លួនឯងបាន។ ជាទូទៅ សកម្មភាពទាំងនោះប្រើប្រាស់បច្ចេកវិទ្យា ឬប្រព័ន្ធអ៊ីនធឺណិត ដើម្បីបង្ហោះសារបន្ទុះបង្អាប់អំពីនរណាម្នាក់ សារដែលមានព័ត៌មាន រូបភាពឬវីដេអូផ្ទាល់ខ្លួនក្នុងន័យធ្វើឱ្យបុគ្គលណាម្នាក់ឈឺចាប់ ឬការផ្ញើសារគម្រាមកំហែង ប្រមាថមើលងាយការផ្សព្វផ្សាយពាក្យចចាមអារ៉ាម និងព័ត៌មានមិនពិតអំពីជនរងគ្រោះ ឬមានគោលបំណងផាត់ពួកគេចេញពីការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអនឡាញ"។ សកម្មភាពបែបនេះ ទោះមិនបានធ្វើឡើងញឹកញាប់ក៏ដោយ ក៏ត្រូវបានចាត់ថាជាការុកគួនឆាឆៅតាមប្រព័ន្ធអនឡាញដែរ។ |

| | |
|---|---|
| **ការស្អប់ខ្ពើមតាមប្រព័ន្ធអនឡាញ ការរើសអើង និងការជ្រុលនិយម**<br>**Cyberhate, Discrimination and extremism** | ការស្អប់ខ្ពើមតាមប្រព័ន្ធអនឡាញ ការរើសអើងនិងការជ្រុលនិយម ជាទម្រង់មួយទៀតនៃអំពើហិង្សាតាមប្រព័ន្ធអ៊ីនធឺណិត។ អំពើទាំងនេះកំណត់គោលដៅទៅលើអត្តសញ្ញាណរួម ជាជាងបុគ្គលណាម្នាក់ជាក់លាក់។ ជារឿយៗសកម្មភាពនេះវាយប្រហារលើបញ្ហាជាតិសាសន៍ និន្នាការផ្លូវភេទ សាសនា សញ្ជាតិ ឬស្ថានភាពអន្តោប្រវេសន៍ ភេទ/យេនឌ័រ និងនយោបាយ ។ |
| **ការអប់រំបែបឌីជីថល**<br>**Digital Education** | ជាការបង្រៀន ឬដំណើរការរៀនសូត្រណាមួយដែលរួមបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល រួមមានទាំងជាទម្រង់អនឡាញ និងក្រៅប្រព័ន្ធអ៊ីនធឺណិត ការប្រើប្រាស់វិធីសាស្ត្រពីចម្ងាយ ដោយផ្ទាល់ ឬរួមបញ្ចូលគ្នានៃវិធីសាស្ត្រទាំងពីរ។ |
| **ការផ្សព្វផ្សាយព័ត៌មានផ្ទាល់ខ្លួនដោយគ្មានការអនុញ្ញាត**<br>**Doxing** | ជាសកម្មភាពបញ្ចេញព័ត៌មានឯកជនរបស់អ្នកដទៃជាសាធារណៈលើប្រព័ន្ធអនឡាញ។ ព័ត៌មានទាំងនោះអាចជាអាសយដ្ឋាន ទីតាំង អាយុ ការងារ ឬព័ត៌មានលម្អិតអំពីការងារ និន្នាការផ្លូវភេទ ឬទិន្នន័យកំណត់អត្តសញ្ញាណផ្ទាល់ខ្លួន ណាមួយផ្សេងទៀត។ |
| **បច្ចេកវិទ្យាសម្រាប់ការអប់រំ**<br>**EdTech** | ការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីគាំទ្រដល់ការបង្រៀន និងការគ្រប់គ្រងគ្រឹះស្ថានអប់រំប្រកបដោយប្រសិទ្ធភាព។ បច្ចេកវិទ្យានេះរួមបញ្ចូលទាំងឧបករណ៍ឌីជីថលផ្សេងៗ ថ្នាលនិងមាតិកាឌីជីថល កម្មវិធីសុសវែរ និងសេវា ដែលជំនួយដល់ការបង្រៀន បំពេញតាមតម្រូវការជាក់លាក់ និងជួយដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់គ្រឹះស្ថានអប់រំ។ |
| **ច្រកជំនួយបន្ទាន់**<br>**Helpline** | ជាប្រព័ន្ធសម្រាប់ផ្តល់នូវការប្រឹក្សាជាសម្ងាត់ និងគាំទ្រដល់អ្នកស្វែងរកជំនួយ ជារឿយៗ ច្រកនេះដើរតួនាទីបញ្ជូលបន្តទៅកាន់អ្នកផ្តល់សេវាផ្សេងៗទៀត។ |
| **ច្រករាយការណ៍បន្ទាន់**<br>**Hotline** | ជាយន្តការរាយការណ៍តាមប្រព័ន្ធអនឡាញ អំពីរូបភាពសម្ភារៈដែលខុសច្បាប់ឬសង្ស័យថាខុសច្បាប់នៅលើប្រព័ន្ធអនឡាញ រួមមានទាំងរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ។ ច្រករាយការណ៍បន្ទាន់ អាចជួយឱ្យសាធារណជនរាយការណ៍ដោយអនាមិក អំពីរូបភាពសម្ភារៈលើប្រព័ន្ធអនឡាញដែលពួកគាត់សង្ស័យថាអាចខុសច្បាប់។ ច្រករាយការណ៍បន្ទាន់មានតួនាទីខុសគ្នាពី ច្រកជំនួយបន្ទាន់។ |

| | |
|---|---|
| **ការរំលោភបំពានដោយប្រើរូបភាពផ្លូវភេទ (ដោយប្រើប្រាស់បច្ចេកវិទ្យា)**<br>**Technology-Facilitated) Image-Based Sexual Abuse** | ជាការបង្កើត ឬការចែកចាយរូបភាពឯកជនដែលមានលក្ខណៈផ្លូវភេទ ដោយមិនមានការព្រមព្រៀង ឬការគម្រាមក្នុងការចែកចាយរូបភាពទាំងនោះ។ ការរំលោភបំពានដោយប្រើរូបភាពផ្លូវភេទ ភាគច្រើនជាបទល្មើសដែលមិនមានការព្រមព្រៀង រួមទាំងការប្រព្រឹត្តិដើម្បីជាការសងសឹក "ការផ្សព្វផ្សាយរូបភាពអាសអាភាសដើម្បីសងសឹក" ឬការចែករំលែកដើម្បីធ្វើឱ្យមានជនរងគ្រោះកើតភាពអាម៉ាស។ ការរំលោភបំពានដោយរូបភាពផ្លូវភេទ និង ការផ្ញើសារផ្លូវភេទ មានលក្ខណៈខុសគ្នាត្រង់ថា ការរំលោភបំពានដោយប្រើរូបភាពផ្លូវភេទជាទម្រង់មួយនៃការរំលោភបំពាន ចំណែកការផ្ញើសារផ្លូវភេទ (Sexting) គឺជាសកម្មភាពដែលមានការព្រមព្រៀងរវាងភាគីពីរ (ឬច្រើន)។ |
| **ការផ្សាយផ្ទាល់ពីការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទកុមារ**<br>**Livestreaming of Child Sexual Abuse and Exploitation**<br>*មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (ឆ្នាំ២០២១) ការបញ្ឈប់ការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ៖ បទពិសោធន៍ និងការអនុវត្តល្អនៅក្នុងប្រទេសមានប្រាក់ចំណូលកម្រិតទាប និងមធ្យម អង្គការយូនីសេហ្វ ទីក្រុងញូវយ៉ក*<br>*ផែនការសកម្មភាពអាស៊ានដើម្បីការពារ កុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច និងការរំលោភបំពានតាមអនឡាញ ឆ្នាំ២០២១-២០២៥* | ជាការផ្សាយផ្ទាល់អំពីរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទកុមារនៅលើប្រព័ន្ធអ៊ីនធឺណិត។ សកម្មភាពនេះមានកើតឡើងនៅក្នុងបន្ទប់ជជែកអនឡាញ ថ្នាលបណ្តាញសង្គម និងថ្នាលទំនាក់ទំនងដែលអាចបង្ហាញជាវីដេអូ។ អ្នកមើលការផ្សាយផ្ទាល់នេះ អាចជាអ្នកទស្សនាអកម្ម (បង់លុយដើម្បីបានមើល) ឬសកម្ម តាមរយៈការមានទំនាក់ទំនងជាមួយកុមារ អ្នករំលោភបំពានផ្លូវភេទកុមារ និង/ឬអ្នកសម្របសម្រួលការរំលោភបំពានផ្លូវភេទកុមារ និងស្នើសុំឱ្យធ្វើសកម្មភាពរំលោភបំពានជាក់ស្តែង។ ទម្រង់មួយទៀតនៃការផ្សាយផ្ទាល់ អាចជាការបង្ខំកុមារឱ្យផលិតផល និងបញ្ជូនរូបភាពសម្ភារៈផ្លូវភេទដោយខ្លួនឯង។<br><br>ផែនការសកម្មភាពអាស៊ាន បានកំណត់និយមន័យការផ្សាយផ្ទាល់ជាការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារជាក់ស្តែង (CSEA) និងត្រូវបានមើលតាមរយៈការចាក់ផ្សាយ (និងជូនកាលមើលតាមវីដេអូថតទុក) លើប្រព័ន្ធអនឡាញ ទោះជនរងគ្រោះ និងជនល្មើសស្ថិតនៅក្នុងប្រទេសផ្សេងគ្នា ឬដូចគ្នាក៏ដោយ។<br><br>ទោះបីជាការផ្សាយផ្ទាល់ អាចជាចេតនាដែលជនល្មើសប្រព្រឹត្តដើម្បីកាត់បន្ថយនូវភស្តុតាងឌីជីថលអំពីបទល្មើសរបស់ខ្លួនក៏ដោយ ការផ្សាយផ្ទាល់ទាំងនេះអាចត្រូវបានគេថតទុក ហើយបង្កើតបានជារូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារថ្មីៗទៀត ដែលអាចចែករំលែកបន្តនៅលើប្រព័ន្ធអនឡាញ។ ជនល្មើសអាចបង់ប្រាក់ដើម្បីឱ្យអ្នកសម្របសម្រួលសម្តែងការរំលោភបំពានជាក់ស្តែងលើកុមារតាមដែលបែបដែលខ្លួនបញ្ជា។ ការទូទាត់ប្រាក់អាចធ្វើឡើងដោយប្រើប្រាស់ប្រព័ន្ធទូទាត់ឌីជីថលច្រើនយ៉ាង រួមទាំងរូបិយប័ណ្ណឌីជីថល (cryptocurrencies) ដែរ។ |

| | |
|---|---|
| **ការជូនដំណឹង និងដកចេញ**<br>**Notice and Takedown Orders**<br>*មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(២០២១) ស្តីពីឧបករណ៍វាយតម្លៃផលប៉ះពាល់លើសិទ្ធិកុមារសម្រាប់ប្រតិបត្តិករទូរសព្ទចល័ត, អង្គការយូនីសេហ្វ ទីក្រុងញូវយ៉ក* | ជាការជូនដំណឹង និងចេញបញ្ជាដោយភ្នាក់ងារអនុវត្តច្បាប់ ឬដោយច្រកវាយការណ៍បន្ទាន់(នៅក្នុងប្រទេសខ្លះ) ទៅកាន់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលជាតិ ឬអន្តរជាតិ (ឧ. ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត ក្រុមហ៊ុនបណ្តាញសង្គម ឬ ប្រព័ន្ធជំនួយការស្វែងរកព័ត៌មាន) អំពីរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ និងលុបចេញមាតិកាទាំងនោះឱ្យបានលឿននៅពេលទទួលបានការជូនដំណឹងរួច។ |
| **ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ**<br>**Online Child Sexual Exploitation and Abuse (OCSEA)**<br>*គោលការណ៍ណែនាំសម្រាប់ការការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ។ អនុម័តដោយក្រុមការងារអន្តរភ្នាក់ងារក្នុងប្រទេសលុចសំបួរ ថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៦*<br>*គោលការណ៍ណែនាំទាក់ទងនឹងការអនុវត្តពិធីសារជម្រើសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារអំពីការជួញដូរកុមារ ពេស្យាចារកម្មកុមារ និងរូបភាពអាសអាភាសកុមារ CRC/C/១៥៦ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១៩ របស់គណៈកម្មាធិការសិទ្ធិកុមារ*<br>*ផែនការសកម្មភាពអាស៊ាន ដើម្បីការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច និងការរំលោភបំពានតាមអនឡាញ ឆ្នាំ២០២១-២០២៥*<br>*សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ឆ្នាំ២០២២* | ជាការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទកុមារដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។<br>ការរំលោភបំពានផ្លូវភេទកុមារអាចធ្វើឡើងតាមប្រព័ន្ធអនឡាញ នៅពេលសកម្មភាពរំលោភបំពានផ្លូវភេទត្រូវបានថតទុកជារូបភាព វីដេអូ ឬសម្លេង ហើយបង្ហោះចូលប្រព័ន្ធអនឡាញក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួនឬចែករំលែកជាមួយអ្នកដទៃ។ ការចូលមើលឬចែកបន្តនូវរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទទាំងនោះម្តងហើយម្តងទៀត បង្កើតជាការរំលោភលើសិទ្ធិកុមារ។<br>ផែនការសកម្មភាពអាស៊ាន កំណត់និយមន័យដូចខាងលើ និងពណ៌នាការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញជា "ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICTs) សម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ ឬបង្កឱ្យកុមាររងការកេងប្រវ័ញ្ចផ្លូវភេទ ឬបង្កឱ្យរូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារអាចត្រូវបានផលិត ទិញ លក់ កាន់កាប់ ចែកចាយ ឬផ្ទេរ។ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ រួមបញ្ចូលការលួងលោម រូបភាពមិនសមរម្យរបស់កុមារដែលត្រូវបានថតដោយការបង្ខំ ការគំរាមកំហែង ការបោកបញ្ឆោត ការបញ្ចុះបញ្ចូល ឬតាមរយៈការចែករំលែកតាមដៃគូ និងប្រើប្រាស់កុមារនៅក្នុងសំឡេង ឬរូបភាពនៃការរំលោភបំពានលើកុមារ"។ |

| | |
|---|---|
| **មុខងារគ្រប់គ្រងដោយឪពុកម្ដាយ**<br>**Parental Control Tools**<br>*អង្គការយូនីសេហ្វ ឆ្នាំ២០២១៖ ឧបករណ៍ស្វ័យវាយតម្លៃផលប៉ះពាល់លើសិទ្ធិកុមារសម្រាប់ប្រតិបត្តិករទូរសព្ទចល័ត (បោះពុម្ពផ្សាយលើកទី២)* | កម្មវិធីសុសវែរដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ជាពិសេសឪពុកម្ដាយគ្រប់គ្រងមុខងារមួយចំនួន ឬទាំងអស់នៃឧបករណ៍ឌីជីថលដែលអាចភ្ជាប់ទៅនឹងអ៊ីនធឺណិតបាន។ កម្មវិធីទាំងនេះអាចដាក់កម្រិតទៅលើការចូលប្រើប្រាស់ គេហទំព័រ ឬសេវាអនឡាញ។ កម្មវិធីមួយចំនួនអាចគ្រប់គ្រងពេលវេលានៃការប្រើប្រាស់ ឧ. ឧបករណ៍ឌីជីថលអាចភ្ជាប់ចូលប្រើប្រាស់អ៊ីនធឺណិតតែនៅចន្លោះម៉ោងកំណត់ជាក់លាក់ប៉ុណ្ណោះ។ កាន់តែទំនើបជាងនេះ កម្មវិធីគ្រប់គ្រងដោយឪពុកម្ដាយ អាចកត់ត្រារាល់សារទាំងអស់ដែលបានផ្ញើ ឬបានទទួល។ កម្មវិធីទាំងនេះត្រូវបានការពារដោយពាក្យសម្ងាត់។<br><br>មុខងារគ្រប់គ្រងដោយឪពុកម្ដាយ ចាំបាច់ត្រូវតែរក្សាតុល្យភាពរវាងសិទ្ធិទទួលបានការការពារ និងសិទ្ធិក្នុងការទទួលបានព័ត៌មាន សេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិឯកជនភាព និងមិនរើសអើង ដូចដែលបានកំណត់នៅក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារ។ មុខងារទាំងអស់នេះ មិនទំនងអាចលុបបំបាត់ហានិភ័យទាំងអស់ចំពោះកុមារលើប្រព័ន្ធអនឡាញបានឡើយ។<br><br>ម្យ៉ាងទៀត ការព្យាយាមគ្រប់គ្រងដូច្នេះ អាចប៉ះពាល់ដល់ផលប្រយោជន៍របស់កុមារ ដែលបានមកដោយការចូលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។ |
| **ទិន្នន័យបុគ្គល**<br>**Personal Data**<br>*បទប្បញ្ញត្តិស្ដីពីកិច្ចការពារទិន្នន័យទូទៅ* | ព័ត៌មានទាំងឡាយណាដែលជាអត្តសញ្ញាណ ឬអាចកំណត់អត្តសញ្ញាណរូបវន្តបុគ្គលបាន |
| **ការបង្ការទប់ស្កាត់**<br>**Personal Data**<br>*អង្គការសុខភាពពិភពលោក (WHO) របាយការណ៍ពិភពលោកស្ដីពីអំពើហិង្សានិងសុខភាព, WHO, ទីក្រុងហ្សឺណែវ ឆ្នាំ២០០២* | អនុវត្តតាមនិយមន័យរបស់អង្គការសុខភាពពិភពលោកអំពី 'ការទប់ស្កាត់ជាចម្បង' ការបង្ការទប់ស្កាត់ ជាការបញ្ឈប់ ការគេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារកុំឱ្យកើតមានឡើង។ |
| **ការរចនាប្រកបដោយឯកជនភាព**<br>**Privacy By Design** | ការរៀបចំ និងដាក់បញ្ចូលយន្តការឯកជនភាព ទៅក្នុងកម្មវិធីទូរសព្ទដៃ កម្មវិធីសុសវែរ ឬផលិតផលណាមួយ ចាប់តាំងពីដំណាក់កាលបំផុសគំនិត រហូតដល់ដំណាក់កាលរចនា និងការអភិវឌ្ឍផលិតផល។ ការធ្វើដូច្នេះ អាចធានាបានថាសិទ្ធិឯកជនភាព និងសេចក្ដីត្រូវការរបស់កុមារ ត្រូវបានគិតគូរដាក់បញ្ចូលទៅក្នុងផលិតផលតាំងពីពេលចាប់ផ្ដើម។ |

| | |
|---|---|
| **គេហទំព័ររាយការណ៍**<br>**Reporting Portal** | ជាទំព័ររាយការណ៍ដែលមានដាក់ក្នុងគេហទំព័រ កម្មវិធីទូរស័ព្ទដៃ ឬ ក្នុងកម្មវិធីទូរស័ព្ទដៃ ដែលប្រជាពលរដ្ឋទូទៅអាចចូលទៅរាយការណ៍អំពីរូបភាពទាំងឡាយណាដែលជាប់សង្ស័យថាជារូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ។ |
| **ការរចនាប្រកបដោយសុវត្ថិភាព**<br>**Safety By Design** | ការរៀបចំ និងដាក់បញ្ចូលយន្តការសុវត្ថិភាព ទៅក្នុងកម្មវិធីទូរសព្ទដៃ កម្មវិធីសុសវែរ ឬផលិតផលណាមួយ ចាប់តាំងពីដំណាក់កាលបំផុសគំនិត រហូតដល់ដំណាក់កាលរចនា និងការអភិវឌ្ឍផលិតផល។ ការធ្វើដូច្នេះ អាចធានាបានថា សិទ្ធិទទួលបានសុវត្ថិភាពនិងការការពារ និងតម្រូវការរបស់កុមារត្រូវបានគិតគូរបញ្ចូលពេញលេញទៅក្នុងផលិតផលតាំងពីពេលចាប់ផ្តើម។ |
| **ការផ្ញើសារផ្លូវភេទ**<br>**Sexting** | ជាការផ្ញើ ឬការទទួលសារដែលមានរូបភាព វីដេអូ ឬអត្ថបទមានលក្ខណៈផ្លូវភេទ ឬបំផុសចំណង់ផ្លូវភេទ។ ការផ្ញើសារផ្លូវភេទ ជាទូទៅ ជាឥរិយាបថមានការព្រមព្រៀងរវាងភាគីពីរ ឬច្រើន ប៉ុន្តែសកម្មភាពនេះអាចក្លាយទៅជាការរំលោភបំពានផ្លូវភេទ ប្រសិនបើរូបភាព វីដេអូ ឬសារទាំងនោះត្រូវបានផ្សព្វផ្សាយ ចែករំលែកដោយមិនមានការយល់ព្រមច្បាស់លាស់ពីភាគីទាំងឡាយ ឬប្រសិនបើមានការបង្ខិតបង្ខំកើតមានឡើង។ |
| **ការគំរាមកំហែងផ្លូវភេទ**<br>**Sexual Extortion or Sextortion of a child**<br>*ផែនការសកម្មភាពអាស៊ាន ដើម្បីការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចនិងការរំលោភបំពានតាមអនឡាញ ឆ្នាំ២០២១-២០២៥*<br>*គោលការណ៍ណែនាំ Luxembourg។* | ជាការជំរិតកុមារឱ្យបម្រើផ្លូវភេទ បង់លុយកាក់ ឬអ្វីផ្សេងទៀត តាមរយៈការគំរាមកំហែងចែករំលែករូបភាពភាពមិនសមរម្យ រួមទាំងរូបភាពបង្កើតឡើងដោយកុមារខ្លួនឯង (ឧ. ដូចជាការគំរាមបង្ហោះរូបភាពមិនសមរម្យរបស់កុមារនៅលើបណ្តាញសង្គមជាដើម)។ |
| **អំពើហិង្សាផ្លូវភេទ**<br>**Sexual Violence**<br>*និយមន័យនៅក្នុង Krug et al. ២០០២, op. cit. (សូមមើលការធ្វើបាបកុមារ)* | សំដៅទៅលើភាពរងគ្រោះផ្លូវភេទគ្រប់ទម្រង់ដែលកើតមានលើមនុស្សពេញវ័យ ឬកុមារ មានដូចជា ការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទកុមារ ការរំលោភសេពសន្ថវៈ ការបំពាបំពានបែបផ្លូវភេទផ្សេងៗ ការរំលោភបំពានដោយប្រើប្រាស់រូបភាពអាសអាភាស ពេស្យាចារនិងការជួញដូរឬការវះកាត់ចេញនូវប្រដាប់បន្តពូជជាដើម (FGM)។ ជារួមអំពើហិង្សាផ្លូវភេទសំដៅដល់សកម្មភាព ឬការប៉ុនប៉ងធ្វើនូវសកម្មភាពទាំងឡាយខាងលើដោយជនណាម្នាក់ដោយបង្ខំទៅលើជនរងគ្រោះមិនថានៅទីកន្លែងណាមួយ ឬដោយទំនាក់ទំនងបែបណានោះទេ។ |

| | |
|---|---|
| **ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល**<br>**Digital Technology Industry Information and Communication Technology Sector**<br>*គោលការណ៍ណែនាំសម្រាប់ឧស្សាហកម្មស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ ឆ្នាំ២០២០ របស់សហភាពទូរគមនាគមន៍អន្តរជាតិ* | សំដៅដល់ក្រុមហ៊ុនដែលមានផ្តល់សេវាឬផលិតផលដូចខាងក្រោម រួមមានជាអាទិ៍៖<br>(ក) ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត ដែលផ្តល់សេវាអ៊ីនធឺណិតល្បឿនលឿនចល័ត និងអចល័ត<br>(ខ) ប្រតិបត្តិករទូរសព្ទចល័ត(អាចជាប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិតដែរ)<br>(គ) កម្មវិធីបណ្តាញសង្គម កម្មវិធីផ្ញើសារ និងកម្មវិធីហ្គេមអនឡាញ<br>(ឃ) ក្រុមហ៊ុនផលិតឧបករណ៍បច្ចេកវិទ្យា និងសុសវែរ ដូចជា ទូរសព្ទដៃ ម៉ាស៊ីនហ្គេម ឧបករណ៍ជំនួយនៅផ្ទះបញ្ជាដោយ សំឡេង អ៊ីនធឺណិតនៃវត្ថុ និងប្រដាប់ប្រដាក្មេងលេងភ្ជាប់នឹង អ៊ីនធឺណិតជាដើម<br>(ង) ក្រុមហ៊ុនផ្តល់សេវាផ្សព្វផ្សាយឌីជីថល (អ្នកបង្កើតមាតិកា អ្នកផ្តល់សេវាបង្ហោះមាតិកាជាដើម)<br>(ឃ) ក្រុមហ៊ុនផ្តល់សេវាផ្សាយផ្ទាល់<br>(ង) ក្រុមហ៊ុននានាផ្តល់សេវារក្សាទុកទិន្នន័យ។ |
| **អំពើហិង្សាលើកុមារ**<br>**Violence against children**<br>*មាត្រា ១៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ឆ្នាំ១៩៨៩* | ជាអំពើហិង្សាគ្រប់ទម្រង់ទាំងអស់ទៅលើរាងកាយ ឬផ្លូវចិត្ត ដូចជាការបង្ករបួសស្នាមនិងការរំលោភបំពាន ការមិនបានមើលថែទាំឬការមើលថែទាំមិនបានត្រឹមត្រូវ  ការធ្វើបាបឬការកេងប្រវ័ញ្ច។ អំពើហិង្សាទាំងនេះរួមបញ្ចូលអំពើហិង្សាលើសតិអារម្មណ៍ស្មារតី និងការរំលោភបំពានផ្លូវភេទ។ |


ESKOLA
BA
UMA

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

unicef
for every child

ការិយាល័យអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា
ជាន់ទី៥ អគារ Exchange Square បន្ទប់លេខ ១៩&២០ ផ្លូវលេខ១០៦
សង្កាត់វត្តភ្នំ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា